# ព័ត៌មានទូទៅអំពីព្រឹទ្ធសភា
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

# HANDBOOK OF THE SENATE OF THE KINGDOM OF CAMBODIA

# INFORMATIONS GÉNÉRALES SUR LE SÉNAT DU ROYAUME DU CAMBODGE

រៀបចំចងក្រងដោយ
អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី

# ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា



# មាតិកា

ទំព័រ


**អារម្ភកថា**..........................................................១-២

I **សេចក្ដីផ្ដើម**......................................................៣-១៩

១.ព្រឹទ្ធសភានីតិកាលទី១........................................៤-៩

២.ព្រឹទ្ធសភានីតិកាលទី២....................................១០-១២

៣.ព្រឹទ្ធសភានីតិកាលទី៣...................................១២-១៧

៤.ព្រឹទ្ធសភានីតិកាលទី៤....................................១៨-១៩

II **ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា**...២០-២៥

III **លក្ខខណ្ឌ និងកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា**.......................................២៦-២៨

IV **ឋានៈ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសមាជិកព្រឹទ្ធសភា**
.........................................................................២៨-៣២

១.អភ័យឯកសិទ្ធិដាច់ខាត..........................................២៩

២.អភ័យឯកសិទ្ធិប្រៀបធៀប...............................២៩-៣២

V រចនាសម្ព័ន្ធព្រឹទ្ធសភា....................................៣២-៤៥
១.រចនាសម្ព័ន្ធនយោបាយ..................................៣២-៣៧
២.រចនាសម្ព័ន្ធរដ្ឋបាល.......................................៣៧-៤៥
VI តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា..៤៦-៥៤
១. មុខងារនីតិកម្ម...............................................៤៦-៤៩
២. មុខងារតាមដានការអនុវត្តច្បាប់..........................៤៩-៥០
៣. មុខងារតំណាង..............................................៥១-៥៣
៤. មុខងារសហប្រត្តិការអន្តរជាតិ...............................៥៣
៥. មុខងារអតិរឌ្ឍស្ថាប័ន.........................................៥៤
VII មុខងារសំខាន់ៗរបស់គណៈកម្មការនានា....៥៤-៥៧
១.មុខងារនីតិកម្ម.................................................៥៤-៥៦
២.មុខងារតាមដានការអនុវត្តច្បាប់ ..................................៥៦
៣.មុខងារព័ត៌មាន ............................................៥៦-៥៧
VIII ថវិកាស្វយ័តរបស់ព្រឹទ្ធសភា.......................៥៧-៥៨
IX ការប្រជុំរបស់ព្រឹទ្ធសភា.................................៥៩-៦៤

X **នីតិវិធីនៃការពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងរបស់ព្រឹទ្ធសភា**..........................................................៦៤-៧១

១-ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចលើសំណើរបស់រដ្ឋសភា......................................៦៤-៦៦

២-គណៈកម្មការទទួលបន្ទុកពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់..........................................៦៦-៦៨

៣-ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនានា សុំដាក់ចូលរបៀបវារៈសម័យប្រជុំព្រឹទ្ធសភា..............................................៦៨-៦៩

៤- ប្រជុំព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង..............៦៩-៧១

XI **ការចូលជាធរមាននៃច្បាប់**..........................៧១-៧២

XII **អំពីការទុកជាការប្រញាប់**..........................៧៤-៧៥

XIII **អំពីការបង្វិលទៅបង្វិលមករវាងរដ្ឋសភា និងព្រឹទ្ធសភា**..............................................៧៦-៧៧

XIV **ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា**...៧៩-៨៤

XV **សេចក្ដីសន្និដ្ឋាន**..........................................៨៤-៨៥

**ឧបសម្ព័ន្ធ** : **សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

# អារម្ភកថា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំចងក្រងសៀវភៅ " **ព័ត៌មានទូទៅអំពីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** " ក្នុងគោលបំណង ផ្តល់ជាសញ្ញាណទូទៅ និងជាជំនួយស្មារតីសម្រាប់អ្នកអាន ដែលចង់សិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា ។

សៀវភៅនេះ ពិពណ៌នាអំពីការរៀបចំ ការប្រព្រឹត្តទៅ និងនីតិវិធីដំណើរការការងារ ដែលឆ្លុះបញ្ចាំងអំពីការអនុ-វត្តមុខងារនីតិកម្ម មុខងារតំណាង មុខងារតាមដានការអនុវត្តច្បាប់ មុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍស្ថាប័ន ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទដ្ឋានគតិយុត្តនានា និងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សូមកោតសរសើរ និងថ្លៃងអំណរគុណ ចំពោះក្រុមការងារនៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី ដែលបានខិតខំរៀបចំចងក្រងឯកសារនេះឡើង ដើម្បីជាជំនួយស្មារតីជួយដល់ការ

ប្រតិបត្តិការងាររបស់មន្ត្រីអគ្គលេខាធិការដ្ឋាន និងជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត និងសាធារណជនទូទៅ ដែលមានបំណងចង់សិក្សាឈ្វេងយល់អំពីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**

# I- សេចក្តីផ្តើម

ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ តាមរយៈកិច្ចប្រជុំរវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណបក្សនយោបាយធំៗទាំងពីរ ដែលទទួលបានអាសនៈនៅរដ្ឋសភា គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ីនប៉ិច នៅថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់សម្តេចព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង ក្នុងស្មារតីលើកកម្ពស់ការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ពង្រឹងស្ថិរភាពនយោបាយ និងបន្តប្រវត្តិសាស្ត្រទ្វិកសភា នៅព្រះរាជាណាចក្រកម្ពុជា ដោយបានឯកភាពធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដើម្បីបង្កើតឱ្យមានព្រឹទ្ធសភាឡើងវិញ ។

ការបង្កើតព្រឹទ្ធសភា គឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រ ដោយបានបង្ហាញនូវពន្លឺថ្មីមួយសម្រាប់ព្រះរាជាណាចក្រកម្ពុជា តាមរយៈការពង្រឹងពង្រីកស្មារតីបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ស្ថិរភាពនយោបាយ និង

ការប្តេជ្ញាចិត្តក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ ។

អនុលោមតាមច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចូលជាធរមាននាថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ ព្រឹទ្ធសភាត្រូវបានបង្កើតឡើង និងបានបើកសម័យប្រជុំលើកទី១ នីតិកាលទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ។

**១. ព្រឹទ្ធសភានីតិកាលទី១ (១៩៩៩-២០០៦)**

ព្រឹទ្ធសភានីតិកាលទី១ កើតឡើងដោយការតែងតាំងសម្រាប់រយៈពេល៥ឆ្នាំ មានសមាជិកចំនួន៦១រូប ក្នុងនោះសមាជិកព្រឹទ្ធសភាចំនួន០២រូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ រីឯប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានរដ្ឋសភា ។ ដោយឡែក សមាជិកដទៃទៀត ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមសមាជិក សមាជិកា នៃគណបក្សនយោបាយទាំងបី (គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី) ដែលមានអាសនៈនៅរដ្ឋសភា ហើយត្រូវបានតែងតាំងដោយ

ព្រះមហាក្សត្រ តាមសំណើរបស់ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភាដែលក្នុងនោះមាន ៖

- គណបក្សប្រជាជនកម្ពុជា (CPP) ៣១រូប
- គណបក្សហ៊្វុនស៊ីនប៉ិច (FUN) ២១រូប
- គណបក្សសមរង្ស៊ី (SRP) ០៧រូប ។

ក្នុងចំណោមសមាជិកព្រឹទ្ធសភានីតិកាលទី១សរុបទាំង៦១រូប មានសមាជិកាចំនួន១០រូប ។

ការរៀបចំ ការប្រព្រឹត្តទៅ និងដំណើរការការងាររបស់ព្រឹទ្ធសភា ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុង និងបទដ្ឋានគតិយុត្តនានារបស់ព្រឹទ្ធសភា និងច្បាប់ពាក់ព័ន្ធ ព្រមទាំងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងនីតិកាលទី១ ព្រឹទ្ធសភាដែលកើតឡើងដោយការតែងតាំង ការបែងចែកអាសនៈនៅក្នុងគណៈកម្មការនានាអនុវត្តដូចរដ្ឋសភានីតិកាលទី២ដែរ គឺយករូបមន្ត ៤+៤+១ មានន័យថា គណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០៤ (គណៈកម្មការ ទី៣, ៤, ៥, ៦) គណបក្សហ៊្វុនស៊ីនប៉ិច ទទួលបានអាសនៈជាប្រធានគណៈ

កម្មការចំនួន០៤ (គណៈកម្មការទី១, ២, ៨, ៩) និងគណបក្សសមរង្ស៊ី ទទួលជាប្រធានគណៈកម្មការចំនួន០១ គឺគណៈកម្មការទី៧ ។ ដោយឡែក អនុប្រធានគណៈកម្មការនានា គណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈចំនួន០៥ (គណៈកម្មការទី១, ២, ៧, ៨, ៩) និងគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានអាសនៈចំនួន០៤ (គណៈកម្មការទី៣, ៤, ៥, ៦) ។

ព្រឹទ្ធសភា មានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ សម្រាប់ដឹកនាំ ចាត់ចែង និងពិនិត្យសម្រេចរាល់ការងារផ្សេងៗ ក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុង ។ ប្រធានព្រឹទ្ធសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ អនុប្រធានទាំងពីរ និងប្រធានគណៈកម្មការនានារបស់ព្រឹទ្ធសភា ជាសមាជិក ។

ព្រឹទ្ធសភានីតិកាលទី១ មានគណៈកម្មការចំនួន០៩ ជាសេនាធិការក្នុងការអនុវត្តមុខងាររបស់ខ្លួន ដែលត្រូវបានបែងចែកទៅតាមវិស័យជាសមត្ថកិច្ច ដូចខាងក្រោម៖

១- គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្ដឹង ។

២- គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ ។

៣- គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។

៤- គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសម្អាត ។

៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ។

៦- គណៈកម្មការនីតិកម្ម ។

៧- គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍ ។

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី ។

៩- គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។

ព្រឹទ្ធសភានីតិកាលទី១ បានបន្តនីតិកាល ចំនួន២ដង (ម្តង១ឆ្នាំ) តាមព្រះរាជក្រឹត្យ ៖

- លើកទី១ : ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣០ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៤ (គិតចាប់

ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៤ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៩) ។

- លើកទី២ : ព្រះរាជក្រឹត្យ នស/រកត/១២០៩/០៧០ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩ (គិតចាប់ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៩ រហូតដល់ព្រឹទ្ធសភានីតិកាលទី២ ចូលកាន់តំណែង) ។

❖ **សម្គាល់** :

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី១ មានសម្ដេច **ជា ស៊ីម** ជាប្រធាន (CPP) ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវ័នមុនីរ៉ាក្ស** ជាអនុប្រធានទី១ (FUN) និងឯកឧត្តម **ញឹក ប៊ុនឆៃ** ជាអនុប្រធានទី២ (FUN) ។ មកដល់ខែសីហា ឆ្នាំ២០០៤ ឯកឧត្តម **ញឹក ប៊ុនឆៃ** បានលាលែងទៅបំពេញការងារក្នុងរាជរដ្ឋាភិបាល ហើយគណបក្សហ៊្វុនស៊ុនប៉ិចបានស្នើតែងតាំងឯកឧត្តម **ប៉ោ ប៊ុនស្រ៊ី** ជំនួស ។

ក្នុងនីតិកាលទី១នេះ ព្រឹទ្ធសភាបានផ្ដួចផ្ដើមគំនិតស្នើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយព្រឹទ្ធសភាបាន

ពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំលើកទី៩ នីតិកាលទី១ ព្រមទាំងក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្ដីសម្រេចលេខ : ០៧០/០០២/ ២០០៥/ កបធ.ច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ។

ច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៦០៥/០២០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៥ ។

អនុលោមតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា ចាប់ពីនីតិកាលទី២ និងនីតិកាលបន្តបន្ទាប់ ព្រឹទ្ធសភាកើតឡើងដោយការបោះឆ្នោតជាអសកលផង ជ្រើសតាំងផង និងចាត់តាំងផង សម្រាប់រយៈពេល៦ឆ្នាំ ។



## ២. ព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២)

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ បានប្រព្រឹត្តទៅ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៦ ។

ព្រឹទ្ធសភានីតិកាលទី២ មានសមាជិកចំនួន៦១រូប ក្នុងនោះ៥៧រូប ត្រូវបានបោះឆ្នោតជាអសកល ០២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង០២រូបទៀតត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប ។

ព្រឹទ្ធសភានីតិកាលទី២ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងចំណោមសមាជិកព្រឹទ្ធសភា ៥៧រូប ដែលបានជាប់ឆ្នោត មានសមាសភាពមកពី ៖

១- គណបក្សប្រជាជនកម្ពុជា (CPP) ចំនួន ៤៥រូប

២- គណបក្សហ្វ៊ុនស៊ិនប៉ិច (FUN) ចំនួន ១០រូប

៣-គណបក្សសមរង្ស៊ី (SRP) ចំនួន ០២រូប ។

ក្នុងចំណោមសមាជិកព្រឹទ្ធសភាសរុបទាំង៦១រូប មាន

សមាជិកាចំនួន០៩រូប ។

ព្រឹទ្ធសភានីតិកាលទី២ មានគណៈកម្មការចំនួន០៩ ដែលក្នុងនោះ តាមរយៈការបោះឆ្នោតជ្រើសរើស និងជ្រើសតាំង ស្របតាមនីតិវិធីកំណត់ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០៥ (គណៈកម្មការទី២, ៣, ៤, ៥, ៦) គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០៣ (គណៈកម្មការទី១, ៨, ៩) និងគណបក្សសមរង្ស៊ី ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន ០១ គឺគណៈកម្មការទី៧ ។ ដោយឡែក អនុប្រធានគណៈកម្មការ គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈចំនួន ០៤ ( គណៈកម្មការទី១, ៦, ៨, ៩ ) និងគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានអាសនៈចំនួន០៥(គណៈកម្មការទី២, ៣, ៤, ៥, ៧) ។

❖ **សម្គាល់ :**

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី២ មាន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ជាប្រធាន (CPP) **សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស** ជាអនុប្រធានទី១ (FUN) និងឯកឧត្តម **ទេព ងន** ជាអនុប្រធានទី២ (CPP) ។



### ៣. ព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី៣ បានប្រព្រឹត្តទៅ នាថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២ ។

ជាលទ្ធផលក្នុងចំណោមសមាជិក ៥៧រូប ដែលជ្រើសតាំងដោយការបោះឆ្នោតមានសមាសភាពមកពី៖

- គណបក្សប្រជាជនកម្ពុជា(CPP)ចំនួន៤៦រូប
- គណបក្សសមរង្ស៊ី(SRP) ចំនួន១១រូប ។

ក្នុងចំណោមសមាជិកព្រឹទ្ធសភានីតិកាលទី៣សរុបទាំង ៦១រូប មានសមាជិកាចំនួន១០រូប ។

ព្រឹទ្ធសភានីតិកាលទី៣ បានបើកសម័យប្រជុំដំបូង នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ក្រោមព្រះរាជាធិបតីភាព ដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

❖ **សម្គាល់** :

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភា មាន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ជាប្រធាន (CPP) **ឯកឧត្តម សាយ ឈុំ** ជាអនុប្រធានទី១ (CPP) និង**ឯកឧត្តម តេព ងន** ជាអនុប្រធានទី២ (CPP) ។

ចាប់ពីដំណើរការសម័យប្រជុំដំបូង និងបន្តរហូតមកដល់ពាក់កណ្តាលនីតិកាលទី៣ គណៈកម្មការនានា នៃព្រឹទ្ធសភាមានចំនួន០៩ ហើយសមាសភាពក្នុងគណៈកម្មការដែលបានជាប់ឆ្នោតតាមរយៈការបោះឆ្នោតជ្រើសរើស និងជ្រើសតាំងស្របតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺមកពីគណបក្សប្រជាជនកម្ពុជាទាំងអស់ ទាំងប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការ ។

ដោយអនុលោមតាមកិច្ចព្រមព្រៀង ស្តីពីដំណោះ

ស្រាយនយោបាយ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជា និងក្រុមការងាររបស់គណបក្សសមរង្ស៊ី បានឯកភាពចុះកិច្ចព្រមព្រៀង ស្តីពីការរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា នៅថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៤ ។

តាមរយៈកិច្ចព្រមព្រៀងខាងលើ ព្រឹទ្ធសភាបានធ្វើវិសោធនកម្មប្រការ១៥នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ប្រការ១៥ ថ្មីនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គណៈកម្មការនានារបស់ព្រឹទ្ធសភាមានដូចខាងក្រោម ៖

១- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត ។
២- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ។
៣- គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។
៤- គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនង

រដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ ។

៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ។

៦- គណៈកម្មការនីតិកម្ម និងយុត្តិធម៌ ។

៧- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការសាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ។

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ។

៩- គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

១០- គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ។

ទន្ទឹមនឹងនេះ សមាសភាពក្នុងគណៈកម្មការទាំង១០

ត្រូវបានរៀបចំកែសម្រួលបោះឆ្នោតជ្រើសរើស និងជ្រើសតាំងឡើងវិញ ។ សមាជិកព្រឹទ្ធសភាពីគណបក្សសមរង្ស៊ីទាំង១១រូប ត្រូវបានបញ្ចូលទៅក្នុងគណៈកម្មការទាំងអស់ ក្នុងនោះមាន អាសនៈប្រធានគណៈកម្មការចំនួន២ គឺគណៈកម្មការទី១ និងទី១០ អនុប្រធានគណៈកម្មការចំនួន២ គឺគណៈកម្មការទី៣ និងទី៧ លេខាធិការគណៈកម្មការចំនួន២ គឺគណៈកម្មការទី១ និងទី១០ ព្រមទាំងសមាជិក៥រូបទៀត បញ្ចូល១រូបៗ ទៅក្នុងគណៈកម្មការទី១,៣,៧,៨ និងទី១០។

| មុខតំណែង | គ/១ | គ/២ | គ/៣ | គ/៤ | គ/៥ | គ/៦ | គ/៧ | គ/៨ | គ/៩ | គ/១០ |
|---|---|---|---|---|---|---|---|---|---|---|
| ប្រធាន | | | | | | | | | | |
| អនុប្រធាន | | | | | | | | | | |
| លេខាធិការ | | | | | | | | | | |
| សមាជិក | | | | | | | | | | |
| សមាជិក | | | | | | | | | | |

❖ **សម្គាល់ :**

ព្រឹទ្ធសភានីតិកាលទី៣ មានសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ជាប្រធាន ឯកឧត្តម **សាយ ឈុំ** ជាអនុប្រធានទី១ និងឯកឧត្តម **ទេព ងន** ជាអនុប្រធានទី២ ។ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភាបានទទួលមរណភាព ។ ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ ២០១៥ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានព្រឹទ្ធសភា និងឯកឧត្តមនៃ **ម៉ៅណា** ជាអនុប្រធានទី១ ព្រឹទ្ធសភានីតិកាលទី៣ ។



### ៨. ព្រឹទ្ធសភានីតិកាលទី៤ (២០១៨-២០២៤)

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៤ ប្រព្រឹត្តទៅនាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ជាលទ្ធផលគណបក្សប្រជាជនកម្ពុជា ទទួលបាននូវអាសនៈទាំងអស់ចំនួន៥៨ សម្រាប់៨ភូមិភាគ នៃព្រះរាជាណាចក្រកម្ពុជា ។

សម្រាប់នីតិកាលទី៤ សមាជិកព្រឹទ្ធសភាសរុបមានចំនួន៦២រូប បង្កើន០១អាសនៈ នៅមណ្ឌលភូមិភាគទី៧ (៥៨រូប ជ្រើសតាំងដោយការបោះឆ្នោត ០២រូបចាត់តាំងដោយព្រះមហាក្សត្រ ០២រូបជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប) ស្របគ្នានឹងរដ្ឋសភាបង្កើន០២អាសនៈនៅមណ្ឌលខេត្តព្រះសីហនុ (រដ្ឋសភានីតិកាលទី៦មានសមាជិកសរុប ចំនួន១២៥រូប) ។

ព្រឹទ្ធសភានីតិកាលទី៤ បានបើកសម័យប្រជុំដំបូងនាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងចំណោមសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ទាំង ៦២រូប មានសមាជិកា ចំនួន ១០រូប ។

❖ **សម្គាល់** :

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភា មានសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ជាប្រធាន ឯកឧត្ដម **នៃ ប៉េណា** ជាអនុប្រធានទី១ និងឯកឧត្ដម **ទេព ងន** ជាអនុប្រធានទី២ ។

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ ឯកឧត្ដម **នៃ ប៉េណា** អនុប្រធានទី១ព្រឹទ្ធសភា បានទទួលមរណភាព ។ ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ឯកឧត្ដម **ស៊ឹម កា** ត្រូវបានព្រឹទ្ធសភាធ្វើការបោះឆ្នោតជ្រើសរើសជាអនុប្រធានទី១ ព្រឹទ្ធសភា ។



## II- ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា

ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា ត្រូវបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ ៦០ថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

ព្រះមហាក្សត្រ ឬព្រះរាជតំណាងទ្រង់ប្រទាន ឬផ្តល់កិត្តិយស ចំពោះការបើកសម័យប្រជុំដំបូង នៃនីតិកាលនីមួយៗ ។

ក្រោយពីព្រះមហាក្សត្រ ឬព្រះរាជតំណាងទ្រង់បាន ឬបានបើកនីតិកាលព្រឹទ្ធសភារួចហើយ បើព្រឹទ្ធសភាមានសមាជិកវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងមូល ព្រឹទ្ធសភាអាចដំណើរការបន្តក្រោមអធិបតីភាពនៃប្រធានបណ្តោះអាសន្ន១រូប ជាសមាជិកព្រឹទ្ធសភាជាប់ឆ្នោត ឬចាត់តាំងអាយុច្រើនជាងគេដែលវត្តមាន ហើយឥតមានបណ្តឹងតវ៉ា ព្រមទាំងសមាជិកព្រឹទ្ធសភាជាប់ឆ្នោត ឬចាត់តាំងចំនួន៥រូប អាយុតិចជាងគេដែលវត្តមាន ជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ ។

ក្រោមការដឹកនាំរបស់ប្រធានបណ្តោះអាសន្ននេះ ព្រឹទ្ធសភា ត្រូវចាប់ផ្តើមការងារដូចតទៅ ៖

ក- ប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។

ខ- បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ។

មិនអាចជជែកពិភាក្សាអ្វីឡើយ នៅក្រោមអធិបតីភាពរបស់ប្រធានបណ្តោះអាសន្ន ។

សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែង ។

មុនចាប់ផ្តើមការងារ ក្រោមអធិបតីភាពនៃប្រធានរបស់ខ្លួន ព្រឹទ្ធសភាដំណើរការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានា ដាច់ដោយឡែកពីគ្នា តាមវិធីបោះឆ្នោតសម្ងាត់ និងអនុម័តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

គណៈកម្មការនីមួយៗ មានសមាជិកយ៉ាងតិចចំនួន ០៥រូប ។

ក្រោយពីបានទទួលការគាំទ្រពីអង្គព្រឹទ្ធសភារួចហើយ មុនចាប់ផ្តើមការងាររបស់ខ្លួន គណៈកម្មការនីមួយៗ ត្រូវប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីបោះឆ្នោតសម្ងាត់ជ្រើសតាំងប្រធាន អនុប្រធាន និងលេខាធិការរបស់គណៈកម្មការនីមួយៗ ។

គណៈកម្មការនីមួយៗ ត្រូវកំណត់តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនឱ្យស្របនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់ជាធរមាន រួចដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច ។




ព្រឹទ្ធសភា នីតិកាលទី ៤
សម័យប្រជុំដំបូង


ហិបឆ្នោត
គណៈកម្មការបោះឆ្នោត




ព្រឹទ្ធសភា នីតិកាលទី ៤
សម័យប្រជុំលើកទី ១




ព្រឹទ្ធសភា នីតិកាលទី ៤
សម័យប្រជុំលើកទី ១

## III- លក្ខខណ្ឌ និងកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត កំណត់ដោយច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង០៦ (ប្រាំមួយ) ឆ្នាំម្ដង នៅថ្ងៃអាទិត្យ សប្ដាហ៍ទី៨ មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា១០២ថ្មី នៃរដ្ឋធម្មនុញ្ញ ។

កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ នីតិកាលព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។ ព្រឹទ្ធសភា មានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភា ចំនួន២(ពីរ)រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភា ចំនួន២(ពីរ)រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

សមាជិកព្រឹទ្ធសភាឯទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈ តាមមណ្ឌល ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា១៣៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មណ្ឌលបោះឆ្នោតរបស់សមាជិកព្រឹទ្ធសភា មានចំនួន៨ភូមិភាគ ។

សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឲ្យភូមិភាគរបស់ខ្លួននោះទេ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថ

កិច្ចគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានា ការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

## IV- **ឋានៈ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសមាជិកព្រឹទ្ធសភា**

ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភាបានកំណត់នូវអភ័យឯកសិទ្ធិសភា ឋានៈ បុព្វសិទ្ធិ វិសមិតភាព និងលក្ខខណ្ឌចាំបាច់នានា ដើម្បីធានាជូនដល់សមាជិកព្រឹទ្ធសភា ក្នុងការបំពេញភារកិច្ច ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ។

សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា ។ អភ័យ

ឯកសិទ្ធិសភា ត្រូវបានចែកចេញជាពីរផ្នែក គឺ ៖

**១/. អត្ថន័យឯកសិទ្ធិដាច់ខាត**

ជាការធានាក្នុងការបញ្ចេញយោបល់ ឬការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយ របស់សមាជិកព្រឹទ្ធសភា នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាសមាជិកព្រឹទ្ធសភា ។

**២/. អត្ថន័យឯកសិទ្ធិដោយប្រៀប**

ជាការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយ ។

សមាជិកព្រឹទ្ធសភា មិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។ ប្រសិនបើបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺអាចអនុញ្ញាតធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនតាមច្បាប់ និងនីតិវិធីបានលុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន ។ ការស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូបណាមួយ ត្រូវធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់

សេចក្ដីថ្លែងហេតុមកជាមួយផង ផ្ញើជូនប្រធានព្រឹទ្ធសភា ។

ការលើកអភ័យឯកសិទ្ធិសភា ក្នុងរយៈពេលសម័យប្រជុំព្រឹទ្ធសភា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់តាមការស្នើសុំពីប្រធាន ឬពីសមាជិកព្រឹទ្ធសភា ចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។
- កូរ៉ុមប្រជុំលើសពី ពីរភាគបី នៃសមាជិកព្រឹទ្ធសភាទាំងមូល ។
- ការអនុម័ត តាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ការលើកអភ័យឯកសិទ្ធិសភា ក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវប្រជុំ និងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ។

សេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីសមាជិកព្រឹទ្ធសភាណា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភាជាបន្ទាន់ ដើម្បីសម្រេច ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងនីតិកាលរបស់ព្រឹទ្ធសភា អាសនៈរបស់សមាជិកព្រឹទ្ធសភា ត្រូវប្រកាសថានៅទំនេរ ក្នុងករណីលាលែង បោះបង់ចោលការងារ មកពីវិសមិតភាព ប្រាសចាកសមាជិកភាព ឬទទួលអនិច្ចកម្ម ។ អាសនៈរបស់សមាជិកព្រឹទ្ធសភា ដែលនៅទំនេរយ៉ាងតិច៦ខែ មុនចប់នីតិកាល ត្រូវបំពេញជំនួសដោយសមាជិកថ្មី ចេញពីប្រភពដើម ដែលមានអាសនៈទំនេរនោះ ដោយមិនចាំបាច់បោះឆ្នោតសាឡើងវិញ ។

មុខងារជាសមាជិកព្រឹទ្ធសភា មានវិសមិតភាពជា

មួយមុខងារសមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងវិសមិតភាពជាមួយនឹងការបំពេញមុខងារសាធារណៈជាសកម្ម រួមទាំងការប្រកបការងារក្នុងវិជ្ជាជីវៈសេរីផងដែរ ។

## V- រចនាសម្ព័ន្ធព្រឹទ្ធសភា

### ១. រចនាសម្ព័ន្ធនយោបាយ

ព្រឹទ្ធសភាមានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ មានភារកិច្ច ដឹកនាំ ចាត់ចែង និងពិនិត្យសម្រេចរាល់សកម្មភាពផ្សេងៗរបស់ព្រឹទ្ធសភា ក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុង ព្រមទាំងមានគណៈកម្មការនានា ដែលទទួលបន្ទុកការងារតាមវិស័យជាសមត្ថកិច្ច ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មានប្រធានព្រឹទ្ធសភាជាប្រធាន និងមានអនុប្រធានទាំងពីរនៃព្រឹទ្ធសភា និងប្រធានគណៈកម្មការនានាជាសមាជិក ។

គណៈកម្មការនានារបស់ព្រឹទ្ធសភា ប្រតិបត្តិការងារទៅតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

## រចនាសម្ព័ន្ធ


គណៈកម្មាធិការអចិន្ត្រៃយ៍
គ.សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត ។
គ.សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ។
គ.ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។
គ. មហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ។
គ.កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ។
គ.នីតិកម្ម និងយុត្តិធម៌ ។
គ. អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ។
គ.សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ។
គ.សាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។
គ. អង្កេត បោស សម្អាត និងប្រឆាំងអំពើពុករលួយ ។

ក្រៅពីគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា និងគណៈកម្មការពិសេស ព្រឹទ្ធសភាមានក្រុមផ្សេងៗដែលបានបង្កើតឡើងតាមបញ្ញត្តិប្រការ១១ថ្មី និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដូចខាងក្រោម ៖

- ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមនយោបាយ/ក្រុមពិភាក្សា)
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨
- ក្រុមសមាជិកាព្រឹទ្ធសភា
- គណៈកម្មការក្រុមសីលធម៌សភារបស់សមា-ជិកព្រឹទ្ធសភា
- អ្នកនាំពាក្យព្រឹទ្ធសភា
- ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយព្រឹទ្ធ-សភា
- ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយបណ្តាស្ថាប័នអន្តរសភា (ក្រុមពហុភាគី) ៖
  - \+ អន្តរសភាអាស៊ាន (AIPA)
  - \+ សហភាពអន្តរសភា (IPU)

+ សភានិយាយភាសាបារាំង(APF)

+ អន្តរសភាកម្ពុជា-ឡាវ-វៀតណាម (CLV)

+ មហាសន្និបាតសភាតំបន់អាស៊ី(APA)

+ វេទិកាសភាអាស៊ីប៉ាស៊ីហ្វិក(APPF)

- ក្រុមមិត្តភាពព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាបណ្តាប្រទេស (ក្រុមទ្វេភាគី) ៖

+ សភានៃសាធារណរដ្ឋបារាំង (FRANCE)

+ សភានៃសហព័ន្ធវាឡូនី-ប្រ៊ុចសែល (FEDERATONWALLONE-BRUXELS)

+ សភាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (LAOS)

+ សភាសាធារណរដ្ឋសង្គមនិយមវៀតណាម (VIETNAM)

+ សភាក្រុមប្រឹក្សានយោបាយប្រជាជនចិន (CHINA)

+ សភាប្រទេសជប៉ុន(JAPAN)

+ សភាអូស្ត្រាលី និងញូវហ្ស៊ីលែន (AUSTRALIA & NEWZEALAND)

+ សភាព្រះរាជាណាចក្រថៃឡង់ដ៍ (THAILAND)

+ សភាទួរគី (TURKEY)

+ សភាសហភាពសហព័ន្ធរុស្ស៊ី (RUSSIA)

+ សភាម៉ុងហ្គោលី (MONGOLIA)

+ សភាកូរ៉េខាងត្បូង (SOUTH KOREA)

+ សភាសាធារណរដ្ឋឥណ្ឌា (INDIA)

+ សភាសហព័ន្ធមីយ៉ាន់ម៉ា (MYANMAR) ។

គណៈកម្មការក្រមសីលធម៌ និងក្រុមទាំងនេះរបស់ព្រឹទ្ធសភាដំណើរការការងារទៅតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងមានរបបថវិកាប្រចាំខែសម្រាប់បំពេញការងារ ។ តួនាទី ភារកិច្ច សមត្ថកិច្ច និងរបបថវិកាប្រចាំខែរបស់ក្រុមទាំងនេះ ត្រូវកំណត់ដោយគណៈកម្មាធិ

ការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

## ២. រចនាសម្ព័ន្ធរដ្ឋបាល

នៅរៀងរាល់ដើមនីតិកាលនីមួយៗ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំព្រឹទ្ធសភាបានហើយ ប្រធានព្រឹទ្ធសភា ដោយមានការឯកភាពពីអនុប្រធានទាំងពីររបស់ខ្លួន ស្នើសុំទៅព្រះមហាក្សត្រតែងតាំងឥស្សរជនជាន់ខ្ពស់មួយរូបជាអគ្គលេខាធិការ និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដើម្បីដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភា រ៉ាប់រងរាល់កិច្ចការរដ្ឋបាល សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ប្រធានព្រឹទ្ធសភា ។

ចាប់ពីចុងនីតិកាលទី២នៃព្រឹទ្ធសភា អគ្គលេខាធិការដ្ឋាន មានរចនាសម្ព័ន្ធចែកចេញជាបីអគ្គនាយកដ្ឋាន និងមានអគ្គាធិការដ្ឋានមួយ ។ មកដល់ខែឧសភា ឆ្នាំ២០២០ តាមសេចក្តីសម្រេចលេខ : ០២៧/០៥២០/ពស/សរ.ខលអ

ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវបានកែសម្រួលឡើងវិញ ។

តាមរចនាសម្ព័ន្ធថ្មីនេះ អគ្គលេខាធិការដ្ឋាន មានអគ្គនាយកដ្ឋានចំនួនប្រាំ និងអគ្គាធិការដ្ឋានមួយ ។

# រចនាសម្ព័ន្ធ


អគ្គលេខាធិការដ្ឋាន
អគ្គាធិការដ្ឋាន
ខុទ្ទកាល័យអគ្គលេខាធិការដ្ឋាន
អគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ
-ន.រដ្ឋបាល
-ន.ហិរញ្ញវត្ថុ
-ន.គ្រប់គ្រងបុគ្គលិក
-ន.អភិវឌ្ឍន៍ធនធានមនុស្ស
-ន.គ្រប់គ្រងអគារ សារពើភ័ណ្ឌ និងសំណង់
-ន.ផែនការ និងសរុប
-អង្គសន្តិសុខ
អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី
-ន.នីតិវិធី
-ន.ភូមិភាគ និងសមូហភាពដែនដី
-លេ. អមគណៈកម្មការទាំង១០
-លេ. គណៈកម្មការក្រុមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា
-លេ. ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយព្រឹទ្ធសភា
-លេ.អមអ្នកនាំពាក្យរបស់ព្រឹទ្ធសភា
អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ
-ន.ព័ត៌មាន
-ន.ព័ត៌មានវិទ្យា (ICT)
-បណ្ណាល័យ
-បណ្ណសារដ្ឋាន
អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ
-ន.ពិធីការ
-ន.ទំនាក់ទំនងអន្តរជាតិ
-ន.ស្រាវជ្រាវកិច្ចការអន្តរជាតិ
អគ្គនាយកដ្ឋានស្រាវជ្រាវ
-ន.ស្រាវជ្រាវច្បាប់
-ន.ស្រាវជ្រាវទូទៅ
-ន.ស្រាវជ្រាវកិច្ចការសភា
-ន.ស្រាវជ្រាវថវិកាសភា

អគ្គនាយកដ្ឋានទាំងប្រាំ មានដូចខាងក្រោម ៖

**ក. អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

មានតួនាទីជាសេនាធិការរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងការផ្តល់សេវាផ្គត់ផ្គង់ មធ្យោបាយធនធាន ថវិកា សម្ភារៈ ផាសុខភាព បរិស្ថាន ការងារ អភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធរូបវន្ត ផលប្រយោជន៍ផ្សេងៗ គ្រប់គ្រង និង អភិវឌ្ឍធនធានមនុស្សឱ្យមានវិជ្ជាជីវៈច្បាស់លាស់ និងឈាន ទៅដល់កម្រិតឯកទេស គ្រប់គ្រងរដ្ឋបាលទំនើប ប្រព័ន្ធ សន្តិសុខទំនើប ព្រមទាំងកសាងផែនការ សរុប ជូនសមាជិក ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

## រចនាសម្ព័ន្ធ



## ខ. អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី

មានតួនាទីផ្តល់សេវាបច្ចេកទេស នីតិវិធី កំណត់ហេតុប្រជុំ សេវាឯកសារគតិយុត្តិ ទិន្នន័យច្បាប់ និងសេវាទ្រទ្រង់សកម្មភាពរបស់គណៈកម្មការ និងក្រុមនានារបស់ព្រឹទ្ធសភា ដើម្បីឱ្យព្រឹទ្ធសភាបំពេញបាននូវមុខងារស្នូលទាំងបី គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ។

### រចនាសម្ព័ន្ធ



## គ. អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ

មានតួនាទីផ្ដល់សេវាគាំទ្រលើកកម្ពស់ប្រសិទ្ធភាពមុខងារព្រឹទ្ធសភា ផ្ដល់សេវាការគ្រប់គ្រង ផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា ឱ្យសាធារណៈជនស្គាល់ ដឹង យល់អំពីសកម្មភាព និងកិត្យានុភាពរបស់ព្រឹទ្ធសភា និងមានទំនាក់ទំនងជាមួយនឹងព្រឹទ្ធសភា ។

### រចនាសម្ព័ន្ធ



### ឃ. អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ

មានតួនាទីទទួលបន្ទុកស្រាវជ្រាវកិច្ចការអន្តរជាតិ ផ្តល់សេវាការងារអន្តរជាតិក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ជំរុញកិច្ចសហប្រតិបត្តិការជាមួយបណ្តាអង្គការអន្តរសភាតំបន់-អន្តរជាតិ និងកិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយសភានៃប្រទេសនានាជុំវិញសកលលោក អង្គទូត អង្គការជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល សមាហរណកម្មព្រឹទ្ធសភាឱ្យកាន់តែទូលំទូលាយក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ និងទទួលបន្ទុកការងារពិធីការជាតិ-អន្តរជាតិ ប្រពៃណី និងពិធីសាសនា ។

## រចនាសម្ព័ន្ធ



### ង. អគ្គនាយកដ្ឋានស្រាវជ្រាវ

មានតួនាទីផ្តល់សេវាសិក្សាស្រាវជ្រាវ និងព័ត៌មានផ្នែកច្បាប់ កិច្ចការទូទៅតាមវិស័យ ថវិកា និងកិច្ចការសភា ដើម្បីគាំទ្រដល់ការប្រតិបត្តិមុខងារស្នូលទាំងបី របស់ព្រឹទ្ធសភា ។

## រចនាសម្ព័ន្ធ



### ច. អគ្គាធិការដ្ឋាន

ជាសេនាធិការរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងការត្រួតពិនិត្យវាយតម្លៃ និងផ្តល់យោបល់ ដើម្បីកែលម្អរាល់សកម្មភាពអនុវត្តការងាររបស់អង្គភាពទាំងអស់ ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុង តាមគោលការណ៍ តាមច្បាប់ និងលិខិតបទដ្ឋាននានា និងមានប្រសិទ្ធភាព ។

## រចនាសម្ព័ន្ធ



## VI- តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា

ភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដែលបញ្ញត្តិដោយមាត្រា១១២ថ្មី នៃរដ្ឋធម្មនុញ្ញ គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ។

ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញកិច្ចការរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន (វាក្យខ័ណ្ឌទី១ មាត្រា៩៩ថ្មី នៃរដ្ឋធម្មនុញ្ញ) ។

ក្នុងនាមជាចំណែកមួយនៃអង្គនីតិប្បញ្ញត្តិ ព្រឹទ្ធសភា មានមុខងារសំខាន់ៗ ដូចខាងក្រោម ៖

### ១. មុខងារនីតិកម្ម

ការពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ព្រឹទ្ធសភាអនុវត្តន៍តាមបទប្បញ្ញត្តិមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ។

ជាទូទៅការពិនិត្យ និងឲ្យយោបល់ ផ្តើមឡើងដោយការបង្ហាញរបាយការណ៍របស់គណៈកម្មការ ការឆ្លើយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តី

ស្នើច្បាប់ ឬបញ្ហាទាំងពួង (ប្រការ៥៧ នៃបទបញ្ជាផ្ទៃក្នុង ព្រឹទ្ធសភា) ។

មាត្រា៩១ថ្មី វាក្យខ័ណ្ឌទី១នៃរដ្ឋធម្មនុញ្ញ បានចែងថា សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមាន សិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ។ ព្រមជាមួយនេះ តាមការបកស្រាយ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ បានបញ្ជាក់នៅត្រង់វាក្យខ័ណ្ឌទី១ « សមាជិកព្រឹទ្ធសភាមួយ រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និង ធ្វើវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន » ។ ប៉ុន្តែ ពុំមានសិទ្ធិលើកសំណើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឡើយ (មាត្រា១៥៣ថ្មី នៃរដ្ឋធម្មនុញ្ញ) ។ បទបញ្ជាផ្ទៃក្នុងរដ្ឋ សភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំង ឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹង ប្រកាសឲ្យប្រើ ។

មាត្រា១១០ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញបានចែង

ថា ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និងសេចក្តីសម្រេចចិត្តទាំងឡាយ ដែលព្រឹទ្ធ-សភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា ។

❖ **សម្គាល់ :**

ចាប់តាំងពីឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០១៩ ព្រឹទ្ធសភាបានផ្តួចផ្តើមគំនិត និងចូលរួមធ្វើសេចក្តីស្នើច្បាប់ ដូចខាងក្រោម ៖

១- ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ (ឆ្នាំ២០០៣) ។

២-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធ-សភា (២០០៥ និង២០១៧) ។

៣-ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា(ឆ្នាំ២០០៨)។

៤- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា (ឆ្នាំ២០១១)។

៥-បទបញ្ជាផ្ទៃក្នុងសមាជរដ្ឋសភា និងព្រឹទ្ធសភា

(ឆ្នាំ២០១១) ។

ព្រឹទ្ធសភាបានស្នើសុំកែសម្រួលសេចក្តីព្រាងច្បាប់ដូចខាងក្រោម ៖

១- សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន (មាត្រា៣ សុំឱ្យលុបចោលពាក្យ "**ជានារី**" ) ។

២-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ (មាត្រា ៣ ចំណុចទី៤ នៃជំពូកទី១ សុំដាក់ថា " **មិនដែលមានទោសជាប់ពន្ធនាគារពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ**" )។

ដោយឡែកសេចក្តីព្រាងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ត្រូវបានព្រឹទ្ធសភាបដិសេធជាអសារបង់ ។

**២. មុខងារតាមដានការអនុវត្តច្បាប់**

ដើម្បីបំពេញមុខងារតាមដានការអនុវត្តច្បាប់ ព្រឹទ្ធសភាមានគណៈកម្មការចំនួន១០ ទទួលខុសត្រូវតាមវិស័យ

ជាសមត្ថកិច្ចរបស់ខ្លួន ។ គណៈកម្មការនីមួយៗ បំពេញការងារទៅតាមតួនាទី ភារកិច្ច និងសមត្ថកិច្ច ដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ។ គណៈកម្មការនីមួយៗ មានផែនការសកម្មភាពរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ ។ ជាពិសេសនៅចន្លោះសម័យប្រជុំនីមួយៗ គណៈកម្មការតែងចុះទៅបំពេញមុខងារនេះ តាមក្រសួង មន្ទីរ រាជធានី ខេត្ត ដើម្បីពិនិត្យមើលការអនុវត្តច្បាប់ និងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច ។

ព្រឹទ្ធសភា ពុំមានសិទ្ធិកោះអញ្ជើញសមាជិករាជរដ្ឋាភិបាល មកសួរដេញដោលចំពោះមុខគណៈកម្មការ ឬក្នុងសម័យប្រជុំពេញអង្គ លើបញ្ហាបច្ចុប្បន្នភាពណាមួយដូចរដ្ឋសភាឡើយ ។ ប៉ុន្តែនៅពេលពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ គណៈកម្មការមានសិទ្ធិអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីព្រាងច្បាប់ មកបំភ្លឺចំពោះមុខគណៈកម្មការ និងក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភាបាន ។

### ៣. មុខងារតំណាង

សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាង ឱ្យភូមិភាគរបស់ខ្លួននោះទេ (មាត្រា២ នៃច្បាប់ស្ដីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា) ។

មាត្រា១០ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បានចែងថា អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ដ្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។

ភាពជាតំណាង ក្រុមប្រឹក្សាឃុំសង្កាត់ នាំឱ្យព្រឹទ្ធសភាមានបេសកកម្មផ្ទាល់របស់ខ្លួន ក្នុងលក្ខណៈជាពិសេសមួយដោយត្រូវផ្សារភ្ជាប់ការងាររបស់ខ្លួនទៅនឹងកិច្ចការពារ និងលើកតម្កើងផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស រួមទាំងភូមិភាគទាំង៨ទៀតផង ។ ដូច្នេះ ព្រឹទ្ធសភាមានកាតព្វកិច្ចចូលរួមចំណែកយ៉ាងខ្ជាប់ខ្ជួន ក្នុងការតាមដានមើលការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហ

មជ្ឈការ ពោលគឺជួយជំរុញធ្វើឲ្យមានការអភិវឌ្ឍ បានត្រឹមត្រូវតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។

ក្នុងចន្លោះសម័យប្រជុំ សមាជិកព្រឹទ្ធសភា ក៏ដូចជាសមាជិកគណៈកម្មការនានា ត្រូវបំពេញការងារជាប្រក្រតីក្នុងព្រឹទ្ធសភា និងចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិភាគរបស់ខ្លួន ដើម្បីផ្តល់ព័ត៌មានជូនតំណាងរបស់ខ្លួន អំពីសកម្មភាពការងាររយៈពេលបីខែ ក្នុងសម័យប្រជុំនីមួយៗ ព្រមទាំងឈ្វេងយល់លម្អិតអំពីសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាម្ចាស់ឆ្នោត នៅក្នុងមណ្ឌលភូមិភាគរបស់ខ្លួន ។ ជាទូទៅ ការអនុវត្តជាក់ស្តែងរបស់ព្រឹទ្ធសភាកន្លងមកនេះ ដើម្បីបំពេញមុខងារតំណាងឱ្យបានសមស្រប ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគនីមួយៗ តែងចុះទៅប្រាស្រ័យទាក់ទងការងារផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងភូមិភាគរបស់ខ្លួន ដើម្បីរៀបចំវេទិកាថ្នាក់ភូមិភាគ ថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយកំណត់នូវប្រធានបទបច្ចុប្បន្នភាពជាក់លាក់ និងបញ្ហាប្រឈមនានា ដើម្បីដោះស្រាយ ព្រមទាំងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍

ពិនិត្យ សម្រេចនៅក្នុងសម័យប្រជុំបន្ទាប់ ។

ដោយឡែក ក្រុមសមាជិកាព្រឹទ្ធសភា បានសកម្ម បំពេញភារកិច្ចរបស់ខ្លួន នៅតាមមូលដ្ឋាននៃភូមិភាគទាំង៨ ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមនានា ដែលកើតមាន ឡើងចំពោះស្ត្រី និងកុមារ សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងតាមរយៈការរៀបចំកម្មវិធីវេទិកា កិច្ចប្រជុំពិគ្រោះយោបល់ ផ្សេងៗ ព្រមទាំងសកម្មភាពមនុស្សធម៌ ផ្តល់នូវអំណោយជា សម្ភារៈ ថវិកា ការនាំក្រុមគ្រូពេទ្យចុះព្យាបាលជំងឺ ជូនស្ត្រី ក្រីក្រ ជនចាស់ជរា និងកុមារ ។

### ៤. មុខងារសហប្រតិបត្តិការអន្តរជាតិ

ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រឹទ្ធសភាបាន បំពេញការងារយ៉ាងសកម្ម ក្នុងការចូលរួមអនុវត្តកាតព្វកិច្ច អន្តរជាតិ និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសភា និងអង្គការសភានានាក្នុងតំបន់ និងពិភពលោក ។ ក្នុង គ្រប់នីតិកាល ព្រឹទ្ធសភាបានចាត់ទុកកិច្ចសហប្រតិបត្តិការ អន្តរជាតិ ជាកម្លាំងស្នូលនៃការអភិវឌ្ឍស្ថាប័ន ។

### ៨. មុខងារអភិវឌ្ឍស្ថាប័ន

ព្រឹទ្ធសភា មានមោទនភាពលើសមិទ្ធផលជាស្នាដៃនៃការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អគ្គលេខាធិការដ្ឋាន គួបផ្សំនឹងកិច្ចសហប្រតិបត្តិការដ៏មានតម្លៃ ទាំងពហុរូបភាព និងពហុវិស័យ ដែលមិនអាចខ្វះបានពីដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញ និងពង្រឹងសមត្ថភាពព្រឹទ្ធសភាទាំងផ្នែកធនធានមនុស្ស និងការអភិវឌ្ឍស្ថាប័ន ។

## VII- មុខងារសំខាន់ៗរបស់គណៈកម្មការនានា

គណៈកម្មការនានារបស់ព្រឹទ្ធសភា គឺជាយន្តការស្នូលជួយទ្រទ្រង់ដល់ដំណើរការអនុវត្តមុខងាររបស់ព្រឹទ្ធសភាក្នុងនាមជាកូនព្រឹទ្ធសភា (Mini-sénats) ។

គណៈកម្មការនានារបស់ព្រឹទ្ធសភា មានមុខងារសំខាន់ៗ ដូចខាងក្រោម :

### ១. មុខងារនីតិកម្ម

កិច្ចការនីតិកម្មរបស់គណៈកម្មការជំនាញ ស្តែងឡើងតាមរយៈការធ្វើរបាយការណ៍របស់គណៈកម្មការ ឬការផ្តល់

យោបល់របស់ខ្លួនទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ឱ្យ ដើម្បីពិនិត្យសិក្សា និងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភាពិនិត្យ និងសម្រេច ។

ក្នុងករណីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍ សម្រេចបញ្ជូនទៅគណៈកម្មការមួយ ឬច្រើនតាមវិស័យជាសមត្ថកិច្ច និងសម្រេចចាត់តាំងគណៈកម្មការណាមួយឱ្យទទួលបន្ទុកធ្វើរបាយការណ៍ និងនាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា ។

គណៈកម្មការជំនាញ មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ទាក់ទងនឹងវិស័យជំនាញរបស់ខ្លួន មិនចាំតែទទួលយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រគល់ឱ្យពិនិត្យសិក្សានោះទេ ។

ប្រធានគណៈកម្មការ កាលបើពិនិត្យសេចក្តីព្រាង

ច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬសំណើសុំកែសម្រួលរួចហើយ ត្រូវធ្វើលិខិតស្នើសុំមកប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសុំដាក់បញ្ចូលក្នុងរបៀបវារៈប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា ។

## ២. មុខងារតាមដានការអនុវត្តច្បាប់

ក្នុងចន្លោះសម័យប្រជុំ សមាជិកព្រឹទ្ធសភា ក៏ដូចជាសមាជិកគណៈកម្មការនានា ត្រូវបំពេញការងារជាប្រក្រតីក្នុងព្រឹទ្ធសភា និងចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិភាគរបស់ខ្លួន ។

គណៈកម្មការនានា ត្រូវមានរបាយការណ៍តាមវិស័យជាសមត្ថកិច្ច និងសមាជិកព្រឹទ្ធសភា ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរពីសកម្មភាពរៀងៗខ្លួន ក្នុងចន្លោះសម័យប្រជុំជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីបូកសរុបរាយការណ៍ជូនសម័យប្រជុំព្រឹទ្ធសភា នាពេលខាងមុខ ។

## ៣. មុខងារផ្តល់ព័ត៌មាន

គណៈកម្មការ មានបេសកកម្មក្នុងការជានាផ្តល់ព័ត៌មានជូនសមាជិក សមាជិកាព្រឹទ្ធសភា អំពីបញ្ហានានា ដែលស្ថិតក្នុងវិស័យជាសមត្ថកិច្ចរបស់ខ្លួន ។ ក្នុងករណីនេះ គណៈ

កម្មការអាចធ្វើការសិក្សាទៅលើព័ត៌មានទាំងឡាយ ដែលចុះផ្សាយក្នុងសារព័ត៌មានជាតិ និងអន្តរជាតិ របាយការណ៍ស្តីពីវឌ្ឍនការងាររបស់ក្រសួង ស្ថាប័នជំនាញ ការរៀបចំសិក្ខាសាលា វេទិកាជាសាធារណៈ ការជួបប្រាស្រ័យជាមួយម្ចាស់ឆ្នោត និងប្រជាពលរដ្ឋនៅក្នុងភូមិភាគ ដើម្បីស្តាប់មតិយោបល់ ឬសំណូមពរ ហើយធ្វើការសិក្សា ពិចារណា និងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា ។

## VIII- **អំពីថវិកាស្វយ័តរបស់ព្រឹទ្ធសភា**

ព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដោយមានការចូលរួមពីតំណាងគណៈកម្មការនានារបស់ព្រឹទ្ធសភា មានភារកិច្ចពិនិត្យ និងលើកយោបល់ក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ព្រឹទ្ធសភា ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីសុំការយល់ព្រមពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាពិនិត្យ សម្រេច ហើយបញ្ជូនសេចក្តីស្នើថវិកានោះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់បញ្ចូលទៅក្នុងគម្រោងថវិកាជាតិ តាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

រាល់ចំណាយថវិការបស់ព្រឹទ្ធសភា ត្រូវមានតម្លាភាព និងធានាផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងសមធម៌ ជូនព្រឹទ្ធសភា គណៈកម្មការនានារបស់ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា ។

បែបបទចំណាយថវិការបស់ព្រឹទ្ធសភា ត្រូវកំណត់ដោយសេចក្តីសម្រេចប្រចាំឆ្នាំ របស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទទួលខុសត្រូវធ្វើរបាយការណ៍ចំណាយថវិកាព្រឹទ្ធសភានៅរាល់ ៦ខែម្តង និងក្នុងរាល់ដំណាច់ឆ្នាំ និងដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាពិនិត្យសម្រេច ក្រោយពីមានការវាយតម្លៃ និងសេចក្តីសន្និដ្ឋានពីគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រមទាំងមានការចូលរួមពីតំណាងគណៈកម្មការនានារបស់ព្រឹទ្ធសភាផង លើកលែងតែរបាយការណ៍ទូទាត់ថវិកាដំណាច់ឆ្នាំ ក្រោយពីគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យសម្រេចហើយ ត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំបញ្ចូលក្នុងសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ ។

## IX- អំពីការប្រជុំរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយៗ មានថិរវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្ដីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាអាចកោះប្រជុំជាវិសាមញ្ញ ។ រាល់ការប្រជុំរបស់ព្រឹទ្ធសភាអាចប្រព្រឹត្តទៅបាន លុះត្រាមានប្រធានដឹកនាំ ហើយត្រូវមានកូរ៉ុមគ្រប់ចំនួនទាំងនៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈក្នុងសម័យប្រជុំនីមួយៗ ។ ការកំណត់ថ្ងៃប្រជុំ ត្រូវធ្វើជាលិខិតផ្ញើទៅជូនសមាជិកព្រឹទ្ធសភា ។ បើមានការកំណត់ផ្ទាល់មាត់ក្នុងពេលប្រជុំ ការកំណត់នេះ ត្រូវធ្វើជាលិខិតផ្ញើទៅសមាជិកព្រឹទ្ធសភា ដែលមិនបានមកប្រជុំ ។ តាមធម្មតាត្រូវកំណត់ ០២ថ្ងៃ មុនពេលប្រជុំ ដោយមានភ្ជាប់ទៅជាមួយនូវរបៀបវារៈប្រជុំ វៀរលែងតែក្នុងករណីប្រញាប់ ។

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា មានកំណត់ហេតុសង្ខេប និងកំណត់ហេតុ

ពិស្តារ ។ កំណត់ហេតុទាំងអស់ ត្រូវតម្កល់ទុកក្នុងបណ្ណសារដ្ឋានព្រឹទ្ធសភា ។

ព្រឹទ្ធសភាអាចកោះប្រជុំជាសម្ងាត់បាន តាមសំណើសុំពីប្រធានព្រឹទ្ធសភា ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ឬពីព្រះមហាក្សត្រ ឬពីប្រធានរដ្ឋសភា ឬពីនាយករដ្ឋមន្ត្រី ។

អាសនានុក្រមរបស់សមាជិកព្រឹទ្ធសភា ត្រូវរៀបតាមក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ។ ក្រុមនីមួយៗត្រូវមានសមាជិកយ៉ាងតិច១០រូប ។ សមាជិកព្រឹទ្ធសភា១រូប អាចចូលជាសមាជិកក្រុមបានតែមួយប៉ុណ្ណោះ ។ ក្រុមនីមួយៗត្រូវមានប្រធាន១រូប និងអនុប្រធាន១រូប ។

សមាជិកព្រឹទ្ធសភា ចាត់តាំងដោយព្រះមហាក្សត្រ ជ្រើសតាំងដោយរដ្ឋសភា និងគណបក្សនយោបាយដែលមានអាសនៈតិចជាងដប់ អាចជ្រើសរើសចូលជាមួយក្រុមណាមួយ តាមការពេញចិត្តរបស់ខ្លួន ។ បញ្ជីរាយនាមរបស់ក្រុមសមាជិកព្រឹទ្ធសភា ត្រូវផ្ញើជូនប្រធានព្រឹទ្ធសភា ។

ក្រុមសមាជិកព្រឹទ្ធសភា បំពេញតួនាទី ដើម្បីប្រមូលផ្តុំបញ្ញាញាណនយោបាយរបស់ព្រឹទ្ធសភា សំដៅបម្រើឱ្យ

ការបញ្ចេញយោបល់របស់តំណាងក្រុមនៅក្នុងសម័យប្រជុំព្រឹទ្ធសភា ។ ពហុនិយមខាងនយោបាយ ត្រូវអនុវត្តដោយថ្លៃថ្នូរ មានគុណធម៌ និងសុជីវធម៌ ក្នុងក្របខ័ណ្ឌនៃក្រមសីលធម៌សមាជិកព្រឹទ្ធសភា គ្មានការរំលោភបំពាន និងគ្មានការរើសអើង សក្តិសមទៅនឹងលក្ខន្តិកៈទូទៅរបស់សមាជិកព្រឹទ្ធសភា ដែលជាតំណាងឱ្យភូមិភាគ និងប្រជាជាតិខ្មែរទាំងមូល ។

ក្រុមសមាជិកព្រឹទ្ធសភា មានភារកិច្ចដូចខាងក្រោម ៖

- រួមគ្នាពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីរៀបចំតំណាងក្រុមថ្លែងយោបល់ក្នុងនាមក្រុមនៅក្នុងសម័យប្រជុំព្រឹទ្ធសភា និងប្រកាន់ជំហររួមរបស់ក្រុមក្នុងការអនុម័ត
- រួមគ្នាផ្តួចផ្តើមគំនិតស្នើច្បាប់ ឬស្នើវិសោធនកម្មច្បាប់
- រួមគ្នាប្រជុំ ដើម្បីចែករំលែកព័ត៌មាន ពិគ្រោះគ្នាកំណត់គោលជំហររបស់ក្រុម ទៅលើបញ្ហាបច្ចុប្បន្នភាពណាមួយ ដែលក្រុមត្រូវយកចិត្តទុកដាក់ក្នុងការថ្លែង ឬប្រកាសជំហរជាសាធារណៈ ។

ជាគោលការណ៍ រយៈពេលបញ្ចេញយោបល់សម្រាប់ក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ត្រូវបានកំណត់ ។ សមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗ ដែលបានសុំចុះឈ្មោះបញ្ចេញយោបល់ អាចនិយាយបាន ២០នាទីយ៉ាងយូរ ។ សមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗ ដែលគ្រាន់តែសុំឆ្លើយតប និយាយបានត្រឹមតែ៥នាទី ប៉ុណ្ណោះ ។

បើប្រធានព្រឹទ្ធសភាយល់ថា ជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សា នោះប្រធានអាចអនុញ្ញាតបន្ថែមពេលឱ្យនិយាយបាន ១០នាទីទៀត ។ ការបន្ថែមនេះអាចឱ្យបន្តបានពីរដងក្នុងប្រធានបទតែមួយ ។ សមាជិកក្នុងក្រុមជាមួយ មានសិទ្ធិសុំបញ្ចេញមតិបន្ថែមក្នុងប្រធានបទដដែល និងក្នុងរយៈពេលដែលនៅសល់ពីការកំណត់ខាងលើ ។

សូមបញ្ជាក់ជូនថា បទប្បញ្ញត្តិអំពីការសុំចុះឈ្មោះបញ្ចេញយោបល់ និងការកំណត់រយៈពេលបញ្ចេញយោបល់ខាងលើ ប្រើសម្រាប់តែសមាជិកព្រឹទ្ធសភាតែប៉ុណ្ណោះ មិនយកមកប្រើសម្រាប់តំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សេចក្តីស្នើច្បាប់ ឬអ្នកជំនាញការពារសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះទេ ។

## គំនូសតាងអាសនៈក្រុមរបស់សមាជិកព្រឹទ្ធសភា រៀបតាមក្រុមសមាជិកនីមួយៗ

(ប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)

ក្រុមទី១ ក្រុមទី២ ក្រុមទី៣ ក្រុមទី៤ ក្រុមទី៥



# គំរូលិខិតស្នើសុំបញ្ចេញយោបល់

**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សម័យប្រជុំលើកទី..... ព្រឹទ្ធសភានីតិកាលទី.....**
**ពាក្យស្នើសុំបញ្ចេញយោបល់ពិភាក្សា**

**ខ្ញុំបាទ/នាងខ្ញុំ** : .....................................................*សមាជិកព្រឹទ្ធសភា ក្រុមទី*.........
**តាមរយៈ** : *ប្រធានក្រុមទី* ...............

**សូមគោរពជូន**
**សម្តេច/ឯកឧត្តម**................................ **ប្រធានព្រឹទ្ធសភា**

*ខ្ញុំបាទ/នាងខ្ញុំ សូមអនុញ្ញាតមានមតិយោបល់លើ:*

១- ..........................................................................................

..................................................................។

២- ..........................................................................................

..................................................................។

*សូម* **សម្តេច/ឯកឧត្តម**............**ប្រធានព្រឹទ្ធសភា** *មេត្តាអនុញ្ញាត តាមការគួរ ។*

*ថ្ងៃ ខែ ឆ្នាំ........... ពុទ្ធសករាជ២៥........*

*រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០..........*

**ហត្ថលេខា**

**ឯកភាព**
**ប្រធានក្រុមទី** ........

## X- នីតិវិធីនៃការពិនិត្យ និងឱ្យយោបល់

តាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូងរួចហើយ ត្រូវបញ្ជូនមកព្រឹទ្ធសភាដើម្បីពិនិត្យ និងឱ្យយោបល់។

ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង តាមនីតិវិធី ដូចខាងក្រោម ៖

**១. ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចលើសំណើរបស់រដ្ឋសភា**

- ពិនិត្យលើទម្រង់ និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបញ្ជូនមក និងសម្រេចបញ្ជូនទៅគណៈកម្មការណាមួយពិនិត្យសិក្សា ទៅតាមវិស័យជាសមត្ថកិច្ច
- ក្នុងករណីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍

សម្រេចចាត់តាំងគណៈកម្មការណាមួយ ឱ្យទទួលបន្ទុកធ្វើរបាយការណ៍។

**២. គណៈកម្មការទទួលបន្ទុកពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់**

- ដំណើរការសុំយោបល់ពីគ្រប់សមាជិកព្រឹទ្ធសភា (យោបល់យល់ព្រម កែសម្រួល បដិសេធជាអសារបង់ ភ្ជាប់ដោយការកត់សម្គាល់ និង/ឬអនុសាសន៍) ជាលាយលក្ខណ៍អក្សរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលសមាជិកព្រឹទ្ធសភាម្នាក់ៗបានទទួល
- ការផ្តល់យោបល់ពីសមាជិកព្រឹទ្ធសភា ត្រូវធ្វើក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរ បើជាការប្រញាប់មកត្រឹមតែ១ថ្ងៃយ៉ាងយូរ មុនគណៈកម្មការប្រជុំ
- សមាជិកព្រឹទ្ធសភាគ្រប់រូប មានភារកិច្ចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកពិនិត្យសិក្សាលម្អិតដោយផ្តោត

លើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខណ្ឌភូមិភាគរបស់ខ្លួន

- ក្រុមសមាជិកព្រឹទ្ធសភានីមួយៗ កោះប្រជុំដើម្បីកំណត់អំពីជំហររបស់ក្រុម និងចាត់តាំងតំណាងក្រុម ដើម្បីថ្លែងពីជំហររបស់ក្រុម ក្នុងសម័យប្រជុំព្រឹទ្ធសភា
- គណៈកម្មការទទួលបន្ទុក ត្រូវប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬតំណាងហត្ថលេខី ម្ចាស់សេចក្តីស្នើច្បាប់ ដោយមានការអញ្ជើញតំណាងគណៈកម្មការនានា ឬតំណាងក្រុមសមាជិកព្រឹទ្ធសភា និងអ្នកជំនាញចូលរួម ដើម្បីពិគ្រោះយោបល់ និងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យ

ប្រជុំព្រឹទ្ធសភា

- ប្រធានគណៈកម្មការទទួលបន្ទុក កាលបើពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬសំណើសុំកែសម្រួលរួចហើយ ត្រូវធ្វើលិខិតស្នើសុំមកប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសុំដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃអង្គប្រជុំព្រឹទ្ធសភា និងនាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិ-ន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា ។

**៣. ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនានា សុំដាក់បញ្ចូលក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភា**

- ប្រធានគណៈកម្មការទទួលបន្ទុក នាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេច
- អង្គប្រជុំត្រូវសម្រេចថា យល់ព្រម ឬមិនយល់

ព្រម ដើម្បីដាក់បញ្ចូលសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ ទៅក្នុងរបៀបវារៈនៃសម័យប្រជុំព្រឹទ្ធសភា ។

**៤. ប្រជុំព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង**

- កូរ៉ុម ត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។ បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល៣០នាទី ក្រោយពេលកំណត់ចាប់ផ្ដើមការប្រជុំ ប្រធានអង្គប្រជុំត្រូវលើកពេលប្រជុំ
- តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្ដីព្រាងច្បាប់ ឬតំណាងហត្ថលេខីម្ចាស់សេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលមកការពារ ត្រូវមានវត្តមាននៅក្នុងសាលប្រជុំ តាមការអញ្ជើញរបស់ប្រធានព្រឹទ្ធសភា
- ដំណើរការប្រជុំ ត្រូវធ្វើតាមរបៀបវារៈ ។ មុនចាប់ផ្ដើមសម័យប្រជុំ ព្រឹទ្ធសភាត្រូវអនុម័តរបៀបវារៈ និងសមាសភាពលេខាធិការសម័យ

ប្រជុំនីមួយៗ

- ការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាង-ច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង នៅក្នុងអង្គប្រជុំព្រឹទ្ធសភា ផ្តើមឡើងដោយការបង្ហាញរបាយការណ៍របស់គណៈកម្មការទទួលបន្ទុក
- អង្គប្រជុំព្រឹទ្ធសភា ពិនិត្យពិភាក្សាលើសេចក្តីសន្និដ្ឋានរួមរបស់គណៈកម្មការទទួលបន្ទុក ។ តំណាងក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ដែលប្រធានអង្គប្រជុំបានអនុញ្ញាតឱ្យមានយោបល់ ត្រូវមានយោបល់តែអំពីរឿង ដែលកំពុងតែពិភាក្សាប៉ុណ្ណោះ
- តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលមកការពារ ត្រូវឆ្លើយបំភ្លឺចំពោះយោបល់របស់សមាជិកព្រឹទ្ធសភា ដែលបានលើកឡើង
- អង្គប្រជុំព្រឹទ្ធសភាពិនិត្យនិងឱ្យយោបល់(យល់

ព្រម ដោយឥតកែប្រែ ទទួលយកយោបល់សុំកែសម្រួល ឬទទួលយកយោបល់សុំបដិសេធជាអសារបង់ )

- បន្ទាប់ពីព្រឹទ្ធសភា បានពិនិត្យ និងឱ្យយោបល់រួចហើយ សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងនេះ ត្រូវបញ្ជូនទៅរដ្ឋសភាវិញ។

## XI- **ការចូលជាធរមាននៃច្បាប់**

រដ្ឋសភា ពេលទទួលបានយោបល់យល់ព្រមលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ពីព្រឹទ្ធសភា ត្រូវបញ្ជូនទៅរាជរដ្ឋាភិបាល ដើម្បីបន្តនីតិវិធីបង្គំទូលថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើ ។

មាត្រា២៨ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ចែងថា «**ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា លើព្រះរាជក្រឹត្យ**

តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី » ។

មាត្រា៩៣ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា «ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេស ក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ » ។

ច្បាប់ដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្ត-លេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលវេលាកំណត់ខាងលើ ។

# គំនូសបំព្រួញ អំពីនីតិវិធីក្នុងការពិនិត្យ និងអនុម័ត
# នៅរដ្ឋសភា និងព្រឹទ្ធសភា




**សម្គាល់ ៖**

(១) ដំណើរការការងារក្នុងរដ្ឋសភា និងព្រឹទ្ធសភា ។

(២) ការបង្វិលទៅបង្វិលមករវាងរដ្ឋសភា និងព្រឹទ្ធ-សភា ។

## XII- **អំពីការទុកជាការប្រញាប់**

ចំពោះពាក្យថា " ***បើជាការប្រញាប់*** " ត្រូវពិនិត្យទៅតាម២ ករណីគឺ ៖

***ករណីទី១*** : ក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់មានមាត្រាណាមួយចែងថា "***ច្បាប់នេះ ត្រូវចាត់ទុកជាការប្រញាប់***" ។ ការប្រញាប់នេះ គឺសំដៅទៅលើ " ***ការប្រញាប់ក្នុងការអនុវត្តច្បាប់*** " ពីព្រោះជាខ្លឹមសារនៃសេចក្តីដែលមានចែងក្នុងច្បាប់តែម្តង ដើម្បីតម្រូវការអនុវត្តឱ្យស្របនឹងមាត្រា៩៣ថ្មី វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ។ ដូច្នេះព្រឹទ្ធសភាមានរយៈពេលធម្មតាសម្រាប់ពិនិត្យ និងឱ្យយោបល់ (មួយខែ) ។

***ករណីទី២*** : មានលិខិតផ្លូវការរបស់រាជរដ្ឋាភិបាល ឬម្ចាស់អត្ថបទនៃសេចក្តីព្រាងច្បាប់ សុំឱ្យរដ្ឋសភាពិនិត្យសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នោះជាការប្រញាប់ ។ ក្នុងករណីនេះ រដ្ឋសភាត្រូវសម្រេចពីពាក្យសុំនោះ ។ ក្រោយពីបានអនុម័តយល់ព្រមលើកដំបូងហើយ រដ្ឋសភាបញ្ជូនមកព្រឹទ្ធសភាដើម្បីពិនិត្យ និងឱ្យយោបល់ដូចមានចែងក្នុងមាត្រា១១៣ថ្មី វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ។ បើគ្មានពាក្យសុំពីរដ្ឋសភាថា ជាការប្រញាប់ទេនោះ ព្រឹទ្ធសភាមានរយៈពេលធម្មតា

គឺមួយខែ ។

**ករណីទី៣** ៖ មានការស្នើសុំពីរដ្ឋសភាឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់ ។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចលើពាក្យសុំនេះ ។ បើព្រឹទ្ធសភាសម្រេចថា គួរទុកជាការប្រញាប់ នោះព្រឹទ្ធសភាត្រូវអនុវត្តតាមប្រការ៣៧ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺត្រូវចុះអត្ថបទនៃសេចក្តីព្រាងច្បាប់នេះ ទៅក្នុងរបៀបវារៈពិភាក្សាមុនគេ ហើយត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលប្រាំថ្ងៃ ។ ប៉ុន្តែបើព្រឹទ្ធសភាយល់ថា មិនគួរទុកជាការប្រញាប់ទេនោះ ព្រឹទ្ធសភាមានរយៈពេលធម្មតាគឺមួយខែ ។

**ករណីទី៤** ៖ រាជរដ្ឋាភិបាល ឬម្ចាស់អត្ថបទនៃសេចក្តីព្រាងច្បាប់ ស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ជាការប្រញាប់ នោះព្រឹទ្ធសភាត្រូវអនុវត្តនីតិវិធីដូចករណីទី៣ដែរ គឺព្រឹទ្ធសភាមានសិទ្ធិក្នុងការសម្រេចថា គួរយល់ព្រមតាមពាក្យសុំឬទេ? បើយល់ព្រមត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលប្រាំថ្ងៃ ហើយបើមិនយល់ព្រម គឺមានរយៈពេលធម្មតាមួយខែដដែល ។

## XIII- អំពីការបង្វិលទៅបង្វិលមករវាងរដ្ឋសភា និងព្រឹទ្ធសភា

ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមជាលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះ ច្បាប់ដែលរដ្ឋសភាបានអនុម័តហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភា សុំឱ្យកែសម្រួលលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ ។

ការបង្វិលទៅវិញទៅមករវាងព្រឹទ្ធសភា និងរដ្ឋសភា

ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យាពេលដែលបានកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍ សម្រាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់ ។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទីពីរនេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសម្រេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

# គំនូសបំព្រួញអំពីការបង្វិលទៅបង្វិលមក
# រវាងរដ្ឋសភា និងព្រឹទ្ធសភា

## មាត្រា១១៣ថ្មី រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា




## វាក្យខណ្ឌទី៣ វាក្យខណ្ឌទី៤ និងវាក្យខណ្ឌទី៥



ក្នុងករណីដែលព្រឹទ្ធសភាបដិសេធ

(មាត្រា១១៣ ថ្មី វាក្យខណ្ឌទី៦ និងទី៧)




## XIV- **ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា**

ព្រឹទ្ធសភា និងរដ្ឋសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិដូចគ្នា តែរដ្ឋសភា និងព្រឹទ្ធសភាមានអត្តសញ្ញាណ និងសមត្ថកិច្ចខុសគ្នា ដូចខាងក្រោម ៖

| រដ្ឋសភា | ព្រឹទ្ធសភា |
|---|---|
| - ចំនួន : សមាជិកយ៉ាងតិច ១២០រូប (មាត្រា៧៦ថ្មីនៃរដ្ឋធម្មនុញ្ញ) | - ចំនួន : សមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល (មាត្រា៩៩ថ្មីនៃរដ្ឋធម្មនុញ្ញ) |
| - ការជ្រើសតាំង : បោះឆ្នោតជាសកល | - ការជ្រើសតាំង : បោះឆ្នោតជាអសកលផង ជ្រើសតាំងដោយរដ្ឋសភាផង និងចាត់តាំងផង |
| - នីតិកាល : ៥ឆ្នាំ | - នីតិកាល : ៦ឆ្នាំ |
| - បេក្ខជន : អ្នកមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច២៥ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត | - បេក្ខជន : អ្នកមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច៤០ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត |
| - អ្នកបោះឆ្នោត : អ្នកមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច១៨ឆ្នាំ | - អង្គបោះឆ្នោត : តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ |

| | |
|---|---|
| - មណ្ឌលបោះឆ្នោត : រាជធានី ខេត្ត<br>- បោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលសួរដេញដោល ដាក់ញត្តិបន្ទោស និងអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល<br>- អាចត្រូវបានរំលាយមុនផុតនីតិកាល បើសិនរាជរដ្ឋាភិបាល ត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល ១២ខែ (មាត្រា៧៨នៃរដ្ឋធម្មនុញ្ញ)។ | ទាំងអស់ក្នុងតំណែង<br>- មណ្ឌលបោះឆ្នោត : ភូមិភាគទាំង៨<br>- សម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាលដែលជាតួនាទីនយោបាយ<br>- មិនអាចរំលាយមុនផុតនីតិកាលបានឡើយ ។ |
| **មុខងារនីតិកម្ម** | |
| -រដ្ឋសភាពិនិត្យ និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ | -ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំង |

| | |
|---|---|
| -រដ្ឋសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល លើ១មាត្រាម្តង ឬលើ១ជំពូកម្តង និងលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល<br><br>-សមាជិករដ្ឋសភាមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល មានសិទ្ធិផ្តួចផ្តើមគំនិតសើរើ ឬផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ។ | ពួងដែលរដ្ឋសភាបានអនុម័តបញ្ជូនមក<br>-ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើរបាយការណ៍របស់គណៈកម្មការ ការឆ្លើយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាលម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង<br>-ព្រឹទ្ធសភាពុំមានសិទ្ធិផ្តួចផ្តើមគំនិតសើរើ និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ។ |
| **មុខងារត្រួតពិនិត្យ** | |
| -រដ្ឋសភាជ្រើសតាំងរាជរដ្ឋាភិបាល ។ រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល និងអាចទម្លាក់សមាជិកគណៈ | -ព្រឹទ្ធសភា មានការកិច្ចសម្របសម្រួលការងារ រវាងរដ្ឋសភា និងរាជរដ្ឋាភិបាល |

| | |
|---|---|
| រដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង | |
| -រដ្ឋសភាមានអំណាចតាមច្បាប់ ក្នុងការចោទសួរដេញដោលនិងអនុម័តញ្ញត្តិបន្ទោសដកហូតតំណែង ឬរំលាយរដ្ឋាភិបាល ។ | -ព្រឹទ្ធសភា អាចតាមដានត្រួតពិនិត្យការងារ និងការអនុវត្តច្បាប់ និងគោលនយោបាយផ្សេងៗ របស់រាជរដ្ឋាភិបាល ។ |
| **មុខងារតំណាង** | |
| -តំណាងរាស្ត្រដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ក្រោយពីបានប្រកាសសុពលភាព និងស្បថចូលកាន់តំណែងរួចហើយ គឺជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ | -សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឱ្យភូមិភាគរបស់ខ្លួននោះទេ |
| -ប្រធានរដ្ឋសភាត្រូវបំពេញ | -ប្រធានព្រឹទ្ធសភាត្រូវបំពេញ |

| | |
|---|---|
| ភារកិច្ចជាប្រមុខរដ្ឋស្តីទី នៅពេលព្រះមហាក្សត្រ និងប្រធានព្រឹទ្ធសភាអវត្តមាន<br>-ប្រធានរដ្ឋសភា គឺជាអនុប្រធានទី១ នៃក្រុមប្រឹក្សារាជសម្បត្តិ ។ | ភារកិច្ចជាប្រមុខរដ្ឋស្តីទី នៅពេលព្រះមហាក្សត្រអវត្តមាន<br>-ប្រធានព្រឹទ្ធសភា គឺជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ ។ |

## XV- សេចក្តីសន្និដ្ឋាន

ចាប់តាំងពីពេលកកើតក្នុងនីតិកាលទី១ រហូតដល់នីតិកាលទី២នេះ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានបំពេញមុខងាររបស់ខ្លួន ក្នុងនាមជាចំណែកមួយនៃអង្គនីតិបញ្ញត្តិ កាន់តែមានភាពចាស់ទុំខាងនយោបាយ មានបទពិសោធន៍ មានមូលដ្ឋានចំណេះដឹងគតិយុត្ត និងមានឯកទេសប្រសើរជាងមុន ។ ព្រឹទ្ធសភាបានដើរតួនាទីយ៉ាងសំខាន់ និងជាដៃគូជាមួយរដ្ឋសភាក្នុងការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ជាតម្រូវការរបស់ជាតិ ។

បច្ចុប្បន្ន វត្តមានរបស់ព្រឹទ្ធសភានៅក្នុងតំបន់ និង

នៅលើឆាកអន្តរជាតិ ត្រូវបានគេទទួលស្គាល់យ៉ាងច្រើន តាមរយៈការចូលរួមចំណែក បំពេញកាតព្វកិច្ចអន្តរជាតិសំខាន់ៗជាច្រើន ដូចជាការអនុម័តសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀង និងកតិកាសញ្ញាអន្តរជាតិទាំងឡាយ ដែលបម្រើឱ្យផលប្រយោជន៍ជាតិ តំបន់ និងអន្តរជាតិ ។

ជាមួយនឹងវឌ្ឍនភាព ក្នុងជំហានទៅមុខជាបន្តបន្ទាប់ ព្រឹទ្ធសភាត្រូវខិតខំបន្ថែម ដើម្បីលើកកម្ពស់សមត្ថភាព ប្រតិបត្តិមុខងារទាំងប្រាំ ប្រកបដោយប្រសិទ្ធភាព និងគុណភាពពិតប្រាកដ ដើម្បីរួមចំណែកលើកកម្ពស់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ។

# ឧបសម្ព័ន្ធ
# សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

- លេខ : ០៣៦/០០២/២០០០ កបធ.ប
  ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០
- លេខ : ០៣៨/០០៤/២០០០ កបធ.ប
  ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០០
- លេខ :១៥៥/០០៣/២០១៥ កបធ.ប
  ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ។

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៣១ /០០៣ /២០០០

ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០

សេចក្ដីសំរេច

លេខ : ០៣៦/០០២/២០០០ កបធ.ច

ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ៨/៤/៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

-បានឃើញបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

-បានឃើញលិខិតលេខ ០៩៥/៥០០/ពស/ជក របស់សម្ដេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០០ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី ជំពូកទី ៨ ថ្មីនៃរដ្ឋធម្មនុញ្ញ

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ប្រធានព្រឹទ្ធសភា បានសុំក្នុងលិខិតលេខ ០៩៥/៥០០/ពស/ជក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០០ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយតែវាក្យខ័ណ្ឌទី ១ នៃមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ ជាពិសេសត្រង់សេចក្ដីថា " បើជាការប្រញាប់ រយៈពេលនោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ " ។

-យល់ឃើញថា យើងអាចលើកយកពាក្យថា " បើជាការប្រញាប់ "មកពិនិត្យបាន ក្នុង ៤ ករណី គឺ :

-១-ករណីដែលក្នុងអត្ថបទនៃសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ មានមាត្រាណាមួយចែងថា : " ច្បាប់នេះ ត្រូវបានចាត់ទុក ជាការប្រញាប់ " ។

-២-ករណីដែលមានលិខិតផ្លូវការរបស់រាជរដ្ឋាភិបាល ឬរបស់ម្ចាស់សេចក្ដីស្នើច្បាប់ សុំឱ្យរដ្ឋសភាពិនិត្យសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់នោះជាការប្រញាប់ ។

-៣-ករណីដែលមានការស្នើសុំពីរដ្ឋសភា ឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់ ។

-៤-ករណីដែលរាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់ ស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់ ។

<u>ករណីទី ១</u> : ករណីដែលក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ មានមាត្រាណាមួយចែងថា : " ច្បាប់នេះ ត្រូវបានចាត់ទុកជាការប្រញាប់ " ។

ជាបឋម យើងគួរធ្វើការវែកញែក រវាង " ការប្រញាប់ក្នុងការធ្វើច្បាប់ " ហើយនិង " ការប្រញាប់ក្នុងការអនុវត្តច្បាប់ " ។

" ការប្រញាប់ក្នុងការធ្វើច្បាប់ " គឺបានន័យថា រដ្ឋសភា ត្រូវខំធ្វើនិងអនុម័តច្បាប់ឱ្យបានរហ័ស ហើយច្រើនតែតាមសំណើសុំរបស់រាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់ ។ ប៉ុន្តែ នេះគ្រាន់តែជាការខិតខំរបស់រដ្ឋសភា មិនមែនជាការបង្ខំរដ្ឋសភាឱ្យធ្វើតាមសំណូមពរនោះទេ ។

" ការប្រញាប់ក្នុងការអនុវត្តច្បាប់ " គឺក្នុងន័យដែលមានចែងក្នុងមាត្រា ៩៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្តីថា : " ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាម នៅទូទាំងប្រទេស ក្រោយថ្ងៃ ប្រកាសឱ្យប្រើ " ។ ពាក្យថា " ចូលជាធរមាន " គឺសំដៅលើការអនុវត្តច្បាប់ ។

ប្រការដែលមានមាត្រាណាមួយចែង ក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ថា : " ច្បាប់នេះ ត្រូវបានចាត់ទុកជាការប្រញាប់ " នោះ គឺសំដៅតែទៅលើ " ការប្រញាប់ ក្នុងការអនុវត្តច្បាប់ " ប៉ុណ្ណោះ ពីព្រោះជាខ្លឹមសារនៃសេចក្តីដែលមានចែងក្នុងច្បាប់តែម្តង ដើម្បីតំរូវការអនុវត្តឱ្យស្របនឹងមាត្រា ៩៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ។ គឺមិនមែនតាមលិខិតមួយផ្សេងដោយឡែក ដែលធ្វើឡើងដោយរាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់ ដើម្បីសុំឱ្យរដ្ឋសភាពិនិត្យជាការប្រញាប់ឡើយ ។

ក្នុងករណីនេះ បើមានត្រឹមតែមាត្រា ក្នុងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ចែងថា " ជាការប្រញាប់ " ប៉ុណ្ណោះ គឺមិនមែនជា " ការប្រញាប់ ក្នុងការធ្វើច្បាប់ទេ " ។ ព្រឹទ្ធសភា មានរយៈពេលធម្មតាគឺ ១ ខែ សំរាប់ពិនិត្យហើយ ឱ្យយោបល់ ។

<u>ករណីទី ២</u> : រាជរដ្ឋាភិបាល ធ្វើលិខិតសុំឱ្យរដ្ឋសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាការប្រញាប់ ទោះបីក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ បានចែង ឬមិនបានចែងថា "ច្បាប់នេះត្រូវបានចាត់ទុក ជាការប្រញាប់ " ក៏ដោយ ។

ក្នុងករណីនេះ រដ្ឋសភាត្រូវសំរេច លើពាក្យសុំនោះ តាមនីតិវិធីដែលមានចែងក្នុងប្រការ ៤៥ និង ៤៦ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា គឺថារាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់ ត្រូវជូនហេតុផលអំពីការ

សុជាការប្រញាប់នោះ ។ ប្រធានរដ្ឋសភានាំសេចក្តីទៅថ្លែងជំរាបរដ្ឋសភា ដើម្បីសុំរដ្ឋសភាសំរេចថា យល់ព្រមទុកជាការប្រញាប់ ឬមិនយល់ព្រម ។

បើរដ្ឋសភាសំរេចយល់ព្រម ពេលនោះរដ្ឋសភាយកសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់មកពិនិត្យពិភាក្សាមុនគេ ស្របតាមប្រការ ៤៤ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។ ក្រោយបានអនុម័តយល់ព្រមលើកដំបូងហើយ រដ្ឋសភាបញ្ជូនមក ព្រឹទ្ធសភា ដើម្បីពិនិត្យនិងឱ្យយោបល់ ដូចមានចែងក្នុងមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ។ បើគ្មានពាក្យសុំ ពីរដ្ឋសភាថា ជាការប្រញាប់ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ ខែ សំរាប់ពិនិត្យនិងឱ្យយោបល់ ។

ករណីទី ៣ : ជាការត្រឹមត្រូវ រដ្ឋសភាអាចនឹងស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះ " ជាការប្រញាប់ " បានដែរ នៅពេលដែលរដ្ឋសភាបញ្ជូនសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ដែលខ្លួនបានអនុម័តយល់ព្រមលើកដំបូងរួចហើយ មកព្រឹទ្ធសភា តាមមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ។ ការស្នើសុំរបស់រដ្ឋសភាឱ្យព្រឹទ្ធសភា ពិនិត្យជាការប្រញាប់នេះ មានចែងក្នុងប្រការ ៤២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ព្រឹទ្ធសភាត្រូវសំរេចលើពាក្យសុំនេះ តាមនីតិវិធីដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺថា រដ្ឋសភាត្រូវជូនហេតុផលជាលាយ-លក្ខអក្សរ ហើយប្រធានព្រឹទ្ធសភានាំសេចក្តីទៅថ្លែងជំរាបព្រឹទ្ធសភា ដើម្បីសុំព្រឹទ្ធសភាសំរេចថា យល់ព្រម ឬមិនយល់ព្រមទុកជាការប្រញាប់ ។

ដូច្នេះ វាអាស្រ័យលើព្រឹទ្ធសភាជាអ្នកសំរេច ថាគួរទុកជាការប្រញាប់ ឬមិនគួរ ទោះបីមានសំណើពីរដ្ឋសភាថា ទុកជាការប្រញាប់ក៏ដោយ ។ បើព្រឹទ្ធសភាយល់ថា គួរទុកជាការប្រញាប់ តាមសំណើរបស់រដ្ឋសភា ពេលនោះ ព្រឹទ្ធសភាត្រូវអនុវត្តតាមប្រការ ៤១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺត្រូវចុះសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ក្នុងរបៀបវារៈ ពិភាក្សាមុនគេ ហើយត្រូវពិនិត្យនិងឱ្យយោបល់ ក្នុងរយៈពេលប្រាំថ្ងៃ ដើម្បីឱ្យស្របនឹងមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ។ បើព្រឹទ្ធសភាយល់ថា មិនគួរទុកជាការប្រញាប់ទេ ព្រឹទ្ធសភាមានរយៈពេល១ ខែ ដូចធម្មតា សំរាប់ពិនិត្យនិងឱ្យយោបល់។

ករណីទី ៤ : រដ្ឋសភាពុំបានសុំទេ ប៉ុន្តែរាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់សុំឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់ ។ នីតិវិធី ដូចក្នុងករណីទី ៣ ដែរ គឺ ត្រូវអនុវត្តប្រការ ៤១ ៤២ និង ៤៣ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។ ព្រឹទ្ធសភា ជាអ្នកសំរេចខ្លួនឯងថា គួរយល់ព្រមតាមសុំឬទេ ។ បើយល់ព្រម ត្រូវពិនិត្យនិងឱ្យយោបល់ ក្នុងរយៈពេល ៥ ថ្ងៃ ។ ប៉ុន្តែ បើមិនយល់ព្រមទេ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ ខែ ដដែល ។

តាមការវិភាគទាំង ៤ ករណីខាងលើនេះមក ព្រឹទ្ធសភាមានរយៈពេលធម្មតា ១ ខែ ក្នុងការពិនិត្យនិងឱ្យយោបល់ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ។ ក្នុងករណីដែលមានពាក្យសុំពីរដ្ឋសភា

ពីរាជរដ្ឋាភិបាល ឬពីម្ចាស់សេចក្តីស្នើច្បាប់ ឱ្យពិនិត្យជាការប្រញាប់ ព្រឹទ្ធសភាមានអំណាចសំរេចខ្លួនឯង ថា ត្រូវទុក ឬមិនត្រូវទុកជាការប្រញាប់ ។

-យល់ឃើញថា របៀបគិតរយៈពេល ឬរបៀបរាប់ថ្ងៃ ពុំមានចែងក្នុងច្បាប់ណាមួយឱ្យបានច្បាស់លាស់ទេ ក្នុងប្រទេសយើង ។ តាមទម្លាប់រដ្ឋបាលក្តី តុលាការក្តី គេមានរបៀបរាប់ថ្ងៃ និងរយៈពេល ពីរយ៉ាង គឺ:

១-របៀបរាប់រយៈពេលគត់ ( ជាភាសាបារាំងគេហៅថា "délai franc" ) ។

២-របៀបរាប់រយៈពេលមិនគត់ ( ជាភាសាបារាំង គេហៅថា " délai non franc " ) ។

<u>របៀបរាប់ទី ១</u> : <u>រយៈពេលគត់</u>

គឺគេមិនរាប់ថ្ងៃទទួល ( ឯកសារ ) ដែលភាសាឡាតាំងហៅថា " dies a quo " និងថ្ងៃដែលត្រូវផុត ដែលភាសាឡាតាំងហៅថា " dies ad quem " ។ ឧបមាថា រយៈពេលគត់ ៥ ថ្ងៃ ។ ថ្ងៃទទួលឯកសារគឺថ្ងៃទី ៥ មិថុនា ហើយនិងថ្ងៃដែលត្រូវផុតគឺថ្ងៃទី ១០ មិថុនា ។ គេមិនរាប់ថ្ងៃទី ៥ មិថុនា ទេ គឺគេចាប់រាប់ពីថ្ងៃទី ៦ មិថុនាទៅ ។ គេមិនរាប់ ថ្ងៃទី ១០ មិថុនា ដែលជាថ្ងៃត្រូវផុតទេ គឺគេរាប់ថ្ងៃទី ១១ មិថុនា ទើបចប់ផុតបរិបូរណ៍ ។ ហើយ គេរាប់ពីម៉ោង ១២ យប់ ( ម៉ោងសូន្យ ) ដល់ម៉ោង ១២ យប់ សំរាប់រាប់មួយថ្ងៃពេញ ។

ដូច្នេះ ក្នុងឧទាហរណ៍ខាងលើនេះ គេត្រូវរាប់ ថ្ងៃទី ១១ មិថុនា រហូតដល់ម៉ោង ១២ យប់ ទើបផុតរយៈពេលគត់ ៥ ថ្ងៃ ។

<u>របៀបរាប់ទី ២ : រយៈពេលមិនគត់</u>

គឺគេមិនរាប់ថ្ងៃទទួល ( ឯកសារ ) ដូចគ្នានឹងរបៀបរាប់ទី ១ ដែរ ។ ប៉ុន្តែ គេរាប់ថ្ងៃដែលត្រូវផុត គឺថ្ងៃទី ១០ មិថុនា រហូតដល់ម៉ោង ១២ យប់ ។

ក្នុងករណីគ្មានការប្រញាប់ គេប្រើរបៀបរាប់ទី ១ ។ រយៈពេលនេះ ច្រើនតែវែង ដូចជា ១ ខែ ឬ ២ ខែ ។ល។

ក្នុងករណី " ការប្រញាប់ " គេប្រើរបៀបទី ២ ។ រយៈពេលនេះច្រើនតែខ្លី ដូចជា ៥ ថ្ងៃ ឬរាប់ម៉ោង ( ៤៨ ម៉ោង ឬ ៧២ ម៉ោង ។ល។ ) គេច្រើនប្រើរបៀបរាប់នេះ សំរាប់កិច្ចការដែលប្រញាប់ ដូចក្នុងករណី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាដើម ។

ក្នុងករណីដែលច្បាប់បានចែងថា " ថ្ងៃគត់ " គេត្រូវអនុវត្តរបៀបរាប់ទី១ គឺ រយៈពេលគត់ ។

របៀបរាប់ថ្ងៃទាំងពីរយ៉ាងនេះ ប្រទេសយើងធ្លាប់ប្រើកាលក្នុងសម័យមុនមានចំបាំង ( ឆ្នាំ ១៩៧០ ) ហើយប្រទេសជាច្រើនក្នុងលោកក៏គេប្រើដែរ ដូចជាប្រទេសបារាំងជាដើម ។

យោងតាមទម្លាប់នេះ មាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញដែលបានបញ្ជាក់ច្បាស់ថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកត្រឹមតែប្រាំថ្ងៃ " បានន័យថា ព្រឹទ្ធសភាត្រូវប្រើ

របៀបរាប់ទី ២ គឺថារបៀបរាប់រយៈពេលមិនគត់ ។

បើថ្ងៃចុងក្រោយដែលត្រូវចប់ ធ្លាក់ចំថ្ងៃឈប់សំរាក ដូចជាថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃបុណ្យដែលច្បាប់អនុញ្ញាតឱ្យឈប់ គេត្រូវរំកិលថ្ងៃនោះរហូតដល់ថ្ងៃចូលធ្វើការទី ១ ពេញមួយថ្ងៃទៀត ។ ប៉ុន្តែបើថ្ងៃឈប់សំរាកស្ថិតនៅចន្លោះថ្ងៃទទួលឯកសារ " dies a quo " និងថ្ងៃផុតកំណត់ " dies ad quem " រយៈពេល ( ៥ ថ្ងៃ ) នោះ ឥតមានប្រែប្រួលឡើយ គឺថាគ្មានរកយកថ្ងៃធ្វើការណាមកជំនួសបានទេ ។ នេះជាទម្លាប់ដែលគេតែងប្រតិបត្តិតាម ជាទូទៅ សឹងតែគ្រប់ប្រទេស ។

---

## សំរេច

**មាត្រា ១** - មាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ទាក់ទងនឹងឃ្លាថា " បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ " ត្រូវបកស្រាយ ដូចមានចែងក្នុងមូលបទខាងលើ ចំពោះការប្រញាប់និងរយៈពេល ។

**មាត្រា ២**- សេចក្ដីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ជាវ៉ិះ ឥស្សរា

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៣៥ / ០០៧ / ២០០០

ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០០

**សេចក្ដីសំរេច**

លេខ : ០៣៨/០០៤/២០០០ កបធ.ច

ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ២០០០

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស /រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៨/១០០០/ពស/អគ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០០ របស់សម្ដេចប្រធានព្រឹទ្ធសភា សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានទៅអគ្គលេខាធិការដ្ឋាន នៃ ក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០០
- បានឃើញឯកសារទទួលពីរដ្ឋសភា ទាក់ទងនឹងការពិភាក្សាលើមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ៩៩ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងជាអាទិ៍ថា ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ។
- យល់ឃើញថា ការងារក្នុងក្របខ័ណ្ឌនីតិបញ្ញត្តិរបស់ព្រឹទ្ធសភា ត្រូវបានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញរួចហើយ ដូច្នេះមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល* " គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ។
- យល់ឃើញថា ព្រឹទ្ធសភាមានភារកិច្ចជួយសម្របសម្រួលការងាររដ្ឋសភា និងរាជរដ្ឋាភិបាល ដើម្បី

ជួយរកដំណោះស្រាយវិបត្តិនយោបាយ នៅពេលណាដែលវិបត្តិនេះកើតឡើង ។ ការងារនេះមានវិសាលភាពទូលំទូលាយ មិនអាចកំរិតព្រំដែនតាមលិខិតបទដ្ឋានអ្វីបានទេ ហើយក៏មិនអាចចែងជាច្បាប់អ្វីបន្ថែមទៀតពីលើមាត្រា ១១២ ថ្មីដែរ ។

-យល់ឃើញថា មាត្រា ១១២ ថ្មី បានផ្តល់សិទ្ធិអំណាចជូនព្រឹទ្ធសភា អាចធ្វើអន្តរាគមន៍គ្រប់ពេលវេលា ចូលទៅជួយដោះស្រាយវិបត្តិតូច ឬ ធំ ក្នុងកិច្ចការនយោបាយរវាងរដ្ឋសភា និងរាជរដ្ឋាភិបាលតាមមធ្យោបាយផ្សេងៗដែលមាន ដោយពុំកំរិតក្របខ័ណ្ឌនៃពេលវេលាឡើយ ។ មាត្រា ១១២ ថ្មី បានផ្តល់កិត្តិយស និងការទុកចិត្តជូនព្រឹទ្ធសភា ជាហេតុបញ្ជាក់ថា តួនាទីសម្របសម្រួលផ្នែកនយោបាយរបស់ព្រឹទ្ធសភា មានសារៈសំខាន់ណាស់ សំរាប់អាយុជីវិតរបស់ប្រទេសជាតិ ។

-យល់ឃើញថា ព្រឹទ្ធសភាមានភាពចាស់ទុំខាងនយោបាយ ដូច្នេះតួនាទីសម្របសម្រួលខាងនយោបាយ នៃព្រឹទ្ធសភា ពិតជាត្រូវបានយកចិត្តទុកដាក់ ដោយរដ្ឋសភា និងរាជរដ្ឋាភិបាល ។

-យល់ឃើញថា តួនាទីនយោបាយរបស់ព្រឹទ្ធសភា ពុំមានអំណាចចាប់បង្ខំឱ្យរដ្ឋសភា និងរាជរដ្ឋាភិបាល ធ្វើតាមព្រឹទ្ធសភាឡើយ ។ ការសម្របសម្រួលរបស់ព្រឹទ្ធសភា អាចចាត់ទុកថា បានលទ្ធផលជាវិជ្ជមាន លុះត្រាតែរដ្ឋសភា និងរាជរដ្ឋាភិបាលព្រមព្រៀងស្រុះស្រួលគ្នា ។

## សំរេច

**មាត្រា ១** -ក្នុងន័យដូចបានបកស្រាយក្នុងមូលបទខាងលើ ភារកិច្ចរបស់ព្រឹទ្ធសភា ក្នុងការសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដែលមានចែងក្នុងមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ។

**មាត្រា ២** -សេចក្តីសំរេចនេះ ធ្វើឡើងនៅរាជធានីភ្នំពេញថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៥៦/០០៣/២០១៥

ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥

**សេចក្តីសម្រេច**

លេខ : ១៥៥/០០៣/២០១៥ កបធ.ច

ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១០៨/០៧១៥/ពស/នវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ វេលាម៉ោង ១៥ និង ៥១ នាទី។

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតលេខ ១០៨/០៧១៥/ពស/នវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដែលស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឡើងស្របនឹងវាក្យខ័ណ្ឌទី១ មាត្រា១៣៦ថ្មី



អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

មាត្រា១៨១ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា១៩ថ្មី មាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នេះមកពិនិត្យបាន

- យល់ឃើញថា មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាន២វាក្យខ័ណ្ឌ ដែលចែងថា :

*"សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។"*

វាក្យខ័ណ្ឌទី១នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់អំពីសិទ្ធិរបស់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី ក្នុងការផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ វាក្យខ័ណ្ឌទី១នេះ មានន័យថា :

- សមាជិកព្រឹទ្ធសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។
- សមាជិករដ្ឋសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។
- សមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភា មានសិទ្ធិរួមគ្នាផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ឬមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។

ការផ្តួចផ្តើមគំនិតធ្វើច្បាប់ និងការផ្តួចផ្តើមគំនិតធ្វើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ពីសំណាក់សមាជិកព្រឹទ្ធសភា ឬពីសមាជិករដ្ឋសភា ឬពីសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភារួមគ្នាជាហត្ថលេខី ត្រូវធ្វើជាសេចក្តីស្នើច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់ ។

- នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។ នាយករដ្ឋមន្ត្រីត្រូវធ្វើជាសេចក្តីព្រាងច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់ ។

វាក្យខ័ណ្ឌទី២នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ មានន័យថា ជាការបញ្ជាក់បន្ថែមទៅលើខ្លឹមសារនៃវាក្យខ័ណ្ឌទី១ ដោយហាមតំណាងរាស្ត្រមិនឱ្យធ្វើវិសោធនកម្មច្បាប់ដែលសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

- យល់ឃើញថា តាមការបកស្រាយខាងលើនេះ សមាជិកព្រឹទ្ធសភាមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់បាន ។

**សម្រេច**

**មាត្រា ១.-** មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

# HANDBOOK OF THE SENATE OF THE KINGDOM OF CAMBODIA

CONTENTS

PREFACE........................................................................ 1

I. INTRODUCTION.................................................... 2

1. First Legislature ....................................................... 2

2. Second Legislature .................................................... 6

3. Third Legislature ....................................................... 8

4. Forth Legislature ……………………………………11

II. ORGANIZATION AND FUNCTIONING OF THE SENATE…………………………………………..12

III. CONDITIONS AND PROCESS OF THE ELECTION OF SENATORS ...................................................... 16

IV. STATUS, PREVILEGE AND IMMUNITY OF THE SENATORS ........................................................... 18

1. Absolute immunity .................................................. 18

2. Comparative immunity ............................................ 18

V. ORGANIZATIONAL STRUCTURE OF THE SENATE ................................................................. 20

1. Political Structure ..................................................... 20

2. Administrative Structure.......................................... 23

VI. ROLE, DUTY AND COMPETENCE OF THE SENATE ................................................................. 31

1. Legislative Function ............................................... 31
2. Oversight Law Enforcement Function ...................... 33
3. Representation Function ......................................... 33
4. International Cooperation Function.......................... 35
5. Institutional Development Function......................... 35
VII. KEY FUNCTIONS OF THE COMMISSIONS ........ 35
1. Legislative Function ............................................. 35
2. Oversight of Law Enforcement ................................ 36
3. Information Dissemination……………………………..37
VIII. AUTONOMOUS BUDGET OF THE SENATE ....... 37
IX. SESSION OF THE SENATE .................................. 38
X. PROCEDURE OF REVIEW AND ADVICE ........... 43
1. Session of the Permanent Committee to Review and Decide on the Request of the National Assembly...... 43
2. Commission in charge of Reviewing on the Bills...... 43
3. Session of the Permanent Committee to Review and Decide on the Request of the Commissions to Incorporate in the Agenda of the Plenary Session of the Senate............................................................. 45
4. Plenary Session of the Senate to Review and Comment on the Bills or other Issues...................................... 45
XI. LEGISLATION COME INTO FORCE .................... 46
XII. REGARDED AS URGENT .................................... 49

XIII. THE PROCESS OF SENDING BACK THE BILLS BETWEEN THE NATIONAL ASSEMLY AND SENATE……………………………………………..50
XIV. DIFFERENCES BETWEEN THE NATIONAL ASSEMBLY AND SENATE ....................................53
XV. CONCLUSION .......................................................57

# PREFACE

The handbook on “General Information of the Senate of the Kingdom of Cambodia” developed by the Secretariat General of Senate, aims to provide general identity and as an add-memoire for readers who wish to explore about the Senate.

It describes about organization, functioning and process of business operation which reflected in the implementation of legislative, representative, oversight of law enforcement, international cooperation and institutional development function of the Senate in line with the Constitution, Law and legal instruments and internal regulation of the Senate.

The Secretariat General of Senate would like to express its appreciation and gratitude to task force of the Directorate General of Legislative Services and Collective Territories with which has done its best efforts developed this handbook as an add-memoire in order to assist work-execution of Secretariat General of the Senate and it is really useful for researchers, students and general publics who wish to learn or explore about the Senate of the Kingdom of Cambodia.

Phnom Penh, 20 February 2020
Secretary General
OUM SARITH

# I. INTRODUCTION

After the election of Members of the National Assembly (MPs) of the Second Legislature through the supreme summit of the two main political parties which have seats at the National Assembly, Cambodian's People Party (CPP) and FUNCINPEC on 12-13 November 1998 under the Presidency of Samdech Preah Borom Ratanak Korth NORODOM SIHANOUK, former King of the Kingdom of Cambodia, at the Royal Palace in the spirit of enhancement of the national unity and reconciliation, strengthening political stability and continue the history of bicameral parliament in the Kingdom of Cambodia by agreed to amend the 1993 Constitution to reestablish the Senate.

The establishment of the Senate is the key political event in the history to show a new light for the Kingdom of Cambodia through strengthening the spirit of national unity and reconciliation, political stability and commitment in building of democracy, liberal multi-party and rule of law.

In accordance with the Amendment of the Constitution of the Kingdom of Cambodia which was promulgated on 8 March 1999, the Senate was established and opened its First Plenary Session, First Legislature on 25 March 1999.

## 1. First Legislature (1999-2006)

The First Legislature of the Senate was established by appointment for 5 years' terms and has 61 Senators, two Senators should be appointed by His Majesty the King, but the President and two Vice Presidents of the Senate should be appointed by His Majesty the King in line with the request of the President of the National Assembly. Besides, other Senators should be elected among members of the three political parties

(CPP, FUNCINPEC, and SRP) which have seats at the National Assembly and appointed by His Majesty the King in accordance with the request of the President of the National Assembly and the Senate, composed of:

- Cambodia's People Party (CPP) 31
- FUNCINPEC (FUN) 21
- Sam Rainsy (SRP) 07

Among the total 61 Senators of the First Legislature, there were 10 Women.

The organization, functioning and working process of the Senate should implement in accordance with the internal regulation and legal instruments of the Senate and relevant laws as well as the Constitution of the Kingdom of Cambodia.

In the first legislature, the Senate was established by appointment, allocation of seats in the commissions was the same practice at the National Assembly of the Second Legislature by using formula 4+4+1, it meant that CPP were chairmen of four commissions ($3^{rd}$, $4^{th}$, $5^{th}$ and $6^{th}$ Commission), FUNCINPEC were chairmen of the four commissions ($1^{st}$, $2^{nd}$, $8^{th}$ and $9^{th}$), SRP was the chairman of one commission ($7^{th}$ Commission). Besides, vice chairman of commissions CPP got five seats ($1^{st}$, $2^{nd}$, $7^{th}$, $8^{th}$ and $9^{th}$) and FUNCINPEC got four seats ($3^{rd}$, $4^{th}$, $5^{th}$ and $6^{th}$).

The Senate has a permanent committee for leading, managing and deciding on different tasks in the conditions defined under the rule of procedure. President of the Senate was the Chairman of the Permanent Committee, two Vice Presidents and chairmen of other commissions are members.

There were nine commissions, in the first legislature, as subordinates for implementing its functions, divided based on the areas of competence as followed:

1. Commission on Human Rights and Reception of Complaints
2. Commission on Finance and Banking
3. Commission on Economic, Planning, Investment, Agriculture, Rural Development and Environment
4. Commission on Interior, National Defense, Investigation and Anti-Corruption
5. Commission on International Cooperation, Media and Information
6. Commission on Legislation
7. Commission on Education, Cults, Culture and Tourism
8. Commission on Health, Social Welfare, labor and Women Affairs
9. Commission on Public Works, Transport, Telecommunication, Post, Industry, Energy and Commerce.

The Senate of the First Legislature continued its legislature twice (once per year) in line with the Royal Decree:

- Firstly, Royal Decree No. SN/RD?0204/030 dated on 17 February 2004 (from 25 March 2004 to 25 March 2005)
- Secondly, Royal Decree No. SN/RD/1205/070 dated on 11 February 2005 (from 25 March 2005 until the Senate of the Second Legislature take place).

- **Remark:**

The Composition of the leaders of Senate of the First Legislature: Samdech Chea Sim, President (CPP), His Royal Highness Sisowath Chivanmonirak, First Vice President (FUN) and H.E. Mr. Nhek Bunchhay, Second Vice President

(FUN). Until August 2004, H.E. Mr. Nhek Buncchay resigned to work in the Royal Government, the FUNCIPEC requested to appoint H.E. Mr. Por Bunsreou, for replacement.

In the first legislature, the Senate initiated a Proposed Law on Election of Senators which was adopted by the National Assembly on 19 May 2005 at the 2$^{nd}$ Plenary Session of the Third Legislature, and the Senate completely reviewed on the format and legal aspect on 30 May 2005 at the 9$^{th}$ Plenary Session of the First Legislature, as well as the Constitutional Council declared that the law is associated with the Constitution through Decision No. 070/002/2005/CC.L dated on 13 June 2005.

This law was promulgated by the Royal Kram No. NS/RK/0605/020 dated on 20 June 2005.

In accordance with the Law on Election of the Senate, from the Second Legislature onward, the Senate has been established by non-universal election either election or appointment for six years.



## 2. Second Legislature (2006-2012)

The election of Senators of the Second Legislature was organized on 22 January 2006.

The Senate of the Second Legislature was composed of 61 Senators, 57 Senators were elected by the non-universal election, 2 Senators were appointed by His Majesty the King and 2 Senators were elected by the Members of the National Assembly by comparative majority election.

The Senate of the Second Legislature was open its first plenary session on 20 March 2006, under the supreme presidency of Samdech Baromneath Norodom SIHAKMONI, King of the Kingdom of Cambodia.

Among the elected 57 Senators were from:

1. Cambodia's People Party (CPP) 45
2. FUNCINPEC (FUN) 10
3. Sam Rainsy Party (SRP) 02.

There were 9 Women Senators among the 61 Senators.

The Senate of the Second Legislature, there were 9 commissions through election and appointment in line with the defined procedures of the Internal Regulation of the Senate, CPP got seats as chairman of 5 commissions (2nd, 3rd, 4th, 5th and 6th), FUNCINPEC attained seats as chairman of 3 commissions (1st, 8th and 9th) and SRP got seats as chairman of 1 commission (7th). Besides that vice chairman of commission, CPP got 4 seats (1st, 6th, 8th and 9th Commission) and FUNCINPEC got 5 seats (2nd, 3rd, 4th, 5th and 7th commission).

- **Remark:**

The composition of the leaders of the Senate of the Second Legislature were: Samdech Akak Moha Thomak Pothisal CHEA SIM, President (CPP), Samdech Chivorn Monirak, First Vice President (FUN) and H.E. Mr. TEP NGORN, Second Vice President (CPP).



### 3. Third Legislature (2012-2018)

The election of Senators for the Third Legislature was held on Sunday, 29 January 2012.

As the result of the election, there were 57 Senators elected from:

| | | |
|---|---|---|
| 1. | Cambodia's People Party (CPP) | 46 |
| 2. | Samrengsy Party (SRP) | 11 |

There were 10 women among 61 Senators of the Third Legislature.

The Senate of the Third Legislature opened its first plenary session on 20 March 2012, under the supreme presidency of Preah Karona Preahbat Samdech Preah Baromneath Norodom SIHAMONI, King of the Kingdom of Cambodia.

- **Remark:**

The composition of leaders of the Senate of the third Legislature were: Samdech Akak Moha Thomak Pothisal CHEA SIM, President (CPP), H.E. Mr. SAY CHHOUM, First Vice President (CPP) and H.E. Mr. TEP NGORN, Second Vice President (CPP).

From the first plenary session and until the middle of the third legislature, there were 9 commissions of the Senate and composed, through the election and appointment in line with its internal regulation, of all members were from the CPP including chairman, vice chairman, secretary and members of all commissions.

Based on the Agreement on Political Settlement dated on 22 July 2014 between the CPP and SRP, working group of CPP and SRP consent to sign the Agreement on Rearrangement of leadership of the Senate on 11 August 2014.

Through the above agreement, Senate amended article 15 of the Internal Regulation of the Senate. Article 15 (new) of the Internal Regulation, the commissions of the Senate are as followed:

1. Commission on Human Rights, Reception of Complaints and Investigation
2. Commission on Finance, Banking and Auditing
3. Commission on Planning, Investment, Agriculture, Water Resources, Meteorology, Rural Development and Environment
4. Commission on Interior, National Defense, Relations between National Assembly and Senate, Inspection and Civil Services
5. Commission on Foreign Affairs, International Cooperation, Media and Information
6. Commission on Legislation and Justice
7. Commission on Education, Youth, Sports, Cults, Religion, Culture, Fine Arts and Tourism
8. Commission on Health, Social Welfare, Veterans, Rehabilitation, labor, Vocational Trainings and Women Affairs
9. Commission on Public Works, Transport, Civil Aviation, Post, Telecommunication, Industry, Mines, Energy, Commerce, Land Management, Urban Planning and Construction.
10. Commission on Investigation and Anti Corruption.

At the same time, the composition of the 10 commissions were modified by reelection and reappointment. 11 Senators from the SRP were composed into all commissions including two seats as chairman of two commissions, 1st Commission and 10th Commission, vice chairman of two commissions, 3rd and 7th Commission, Secretary of two commissions, 1st and 10th Commission, as well as 5 Senators, each of them was assigned in the 1st, 3rd, 7th, 8th, and 10th Commission.

| Positions | C.1 | C.2 | C.3 | C.4 | C.5 | C.6 | C.7 | C.8 | C.9 | C.10 |
|---|---|---|---|---|---|---|---|---|---|---|
| Chairman | | | | | | | | | | |
| Vice-Chairman | | | | | | | | | | |
| Secretary | | | | | | | | | | |
| Member | | | | | | | | | | |
| Member | | | | | | | | | | |

- **Remark**

The Senate of the Third Legislature were composed of Samdech Akak Thomak Pothisal CHEA SIM, President, H.E. Mr. SAY CHHOUM, First Vice President, and H.E. Mr. TEP NGORN, Second Vice President. On 8 June 2015, Samdech Akak Thomak Pothisal CHEA SIM passed away. In the extraordinary session on 9 June 2015, Samdech Vibol Sena Pheakdey SAY CHHOUM, was elected as the President, H.E. Mr. NAY PENA, First Vice President of the Senate of the Third Legislature.



## 4. Fourth Legislature (2018-2024)

The election of the Senators for the Fourth Legislature was held on 25 February 2018. As the result, CPP attained all the 58 seats for eight regions of the Kingdom of Cambodia.

For the Fourth Legislature, there were 58 Senators in total increased one seat in the 7th Region (58 Senators were elected, 02 Senators were appointed by His Majesty the King, 02 Senators were elected by the National Assembly by comparative majority votes) in line with the National Assembly has also increased two seats in Preah Sihanouk Province (National Assembly of the 6th Legislature has 125 MPs).

The Senate of the Forth Legislature opened its first plenary session on 23 April 2018, under the supreme presidency of Samdech Preah Baromneath Norodom SIHAMONI, King of the Kingdom of Cambodia.

There were 10 Women Senators among the 62 Senators of the Fourth Legislature.

- **Remark**

The composition of leaders of the Senate of the Second Legislature were: Samdech Vibol Sena Pheakdey SAY CHHOUM, President, H.E. Mr. NAY PENA, First Vice President and H.E. Mr. TEP NGORN, Second Vice President.

On 29 September 2018, H.E. Mr. NAY PENA, First Vice President of the Senate passed away. In the extraordinary session of the Senate on 11 October 2018, H.E. Mr. SIM KA was elected as the First Vice President of the Senate.



## II. Organization and Functioning of the Senate

The organization and functioning of the Senate has been defined in the rule of procedure of the Senate.

The Senate shall hold its first session within sixty days after its election upon the call by His Majesty the King.

The Senate, at the opening sitting, is honored by the attendence of His Majesty, the King or his representative.

After the His Majesty the King or Representative began the legislature of the Senate, if the Senate has Senators present more than half of the whole Senators, it can proceed under the presidency of an interim president who is elected or designate anyone who is older and present, without any complaint as well as elected Senators or designate five Senators who are younger and present as secretaries assisting the president.

Under the leadership of this interim president, the Senate should begin their business as followed:

**a.** Declaring validity of the legislature of each Senator

**b.** Electing the President and Two Vice Presidents of the Senate

The senate shall not be opened for debate under the chairmanship of the interim president.

All Senators should take the oath before taking office.

Before begin the work under the presidency of its presidents, the Senate proceeds the election of members of commissions separately under the confidential vote and adopts the rule of procedure of the Senate, defines the organization and functioning of the Senate by absolute majority vote of the whole Senators.

Each commission has at least five members.

After attaining support from the plenary session of the Senate, prior to start their business, each commission should held its internal meeting to elect chairman, vice chairman and secretary of each commission confidentially.

Each commission should define its role, duty and competency in line with the Constitution, rule of procedure of the Senate and existing laws and submit to Permanent Committee to review and decide.







ហិបឆ្នោត




ព្រឹទ្ធសភា នីតិកាលទី ៤
សម័យប្រជុំលើកទី ១





## III. Conditions and process of the election of Senators

Organizing procedures and functioning of the appointment and election of the Senators as well as defining the voters, electoral colleagues, and constituencies which are defined by the Law on the Election of Senators.

The election of Senators should be held once per 06 (six) years on Sunday, eighth week prior to the end of the sixth year of the legislature of the Senate, except the case which is stipulated in the provision of Article 102 (new) of the Constitution.

The date of election should be defined and declared by the Prime Minister upon the request of Minister of Interior. The Legislature of Senate should be ended, when the new Senate takes office. The Senate should have more than half of the total Members of the National Assembly.

Two Senators shall be appointed by His Majesty the King.

Two Senators shall be elected in comparative majority by the National Assembly.

Other Senators shall be elected by non-universal, indirect and by means of secret ballot.

The election of Senators shall be implemented through proportional representative system and seat allocation by constituencies shall be done in formulation of the highest average as stated in Article 135 of the Law on Election of the Members of the National Assembly.

The electoral constituencies shall be classified into eight regions.

Incumbent Senators are the representatives of the entire Khmer Citizen by not only represent their regions.

The administration of the election of the Senators is the competence of the National Election Committee (NEC).

The Constitutional Council (CC) has competence to ensure, protect, respect and, interpret the Constitution, and laws passed by the National Assembly and the Senate completely reviewed.

The Constitutional Council (CC) has right to review and decide on any conflict related to the election of Members of the National Assembly and the election of the Senators.

The decision of the Constitutional Council (CC) is the final decision to conclude any appeal.

## IV. Status, Privilege and Immunity of the Senators

Law on Statute of the Senators defines the parliamentary immunity, status, inequality and necessary conditions to ensure that the Senators that implement their duties in line with the Constitution, law and legal instruments of the Kingdom of Cambodia.

The Senator has parliamentary immunity. The parliamentary immunity is divided into two categories:

### 1. Absolute immunity

The assurance of expression of opinion or ideas in the process of law adoption of the Senators within the framework of role performance as Senators.

### 2. Comparative immunity

The assurance of any Senator who shall not in any case be accused, arrested or comprehended.

No Senator can be in any case able to abuse this immunity that affect the reputation of another individual, good tradition of

society, public order and national security. If he/she commits any criminal act, it shall be allowed to be accused, arrested or detained in line with laws and procedures when his/her parliamentary impunity is lifted. The request of parliamentary immunity to be lifted shall be done by the prosecutor attached to the appeal court through the Minister of Ministry of Justice by attached with the explanatory note submitted to the President of the Senate.

In case of parliamentary immunity release during the plenary session of the Senate shall implement the procedures as followed:

- The Senate shall convene a confidential session upon the request of the President or at least one ten of the Senators, His Majesty the King, Prime Minister or President of the National Assembly,
- Quorum of the session shall be more than two third of the entire Senators,
- Approval shall be done by two third majority of the entire Senators.

The release of parliamentary immunity within the recess of the Senate, the Permanent Committee of the Senate shall convene and adopt in line with the rule of procedure of the Senate.

Decision of the Permanent Committee shall be put forward to the next plenary session of the Senate to adopt based on the two third of the whole Senators.

In case of any Senator committed actual criminal act, competent ministry can accuse, arrest, detain or comprehend and shall report to the Senate or Permanent Committee of the Senate

in between the interval session of the Senate as urgent mater to decide.

In all above cases, detention and accusation of any Senator shall be suspended, if the Senate expresses to suspend based on the two forth of the whole Senators.

In the legislature of Senate, seat of the Senator shall be declared as vacant in case of resignation, incompatibility, and dissolution of parliamentarian or diseased. The seat of the Senator is vacant at least six months prior to the end of the legislature shall be replaced by new Senator comes from authentic source of the vacant seat by not re-electing.

The function of Senator is incompatible with actively exercising any public functions as the Member of the National Assembly, Royal Government, member of the Constitutional Council, and other functions in the civil services including any free professional performance.

## V. Organizational Structure of the Senate

### 1. Political Structure

The Senate has a Permanent Committee which has duty, lead, manage and decide on other activities of the Senate within the conditions defined in the rule of procedure as well as commissions which are responsible for area of their competence.

The Permanent Committee consists of the President of the Senate, two Vice- Presidents and Chairmen of all Commissions of the Senate are the members.

The Commissions of the Senate executes its work in line with the defined role, duty and competence by the Permanent Committee.

ORGANIZATIONAL STRUCTURE




Besides the Permanent Committee, commissions and special commission, the Senate has other groups which have been established in compliance with the Article 11 (new) and Article 38 of the rule of procedure of the Senate as followed:

- Parliamentary Group (political/debate group)
- Eight regional Groups of Senators
- Women Caucus
- Commission on Parliamentary Code of Conduct of Senators
- Spokespersons of the Senate
- Focal Person of Anti-Corruption Group of the Senate
- Senator Group in charge of collaboration with inter-parliamentary institutions (multilateral):
  - ASEAN Inter-Parliamentary Association (AIPA)
  - Inter-Parliamentary Union (IPU)

    - Assemblée Parlementaire de la Francophonie (APF)
    - Cambodia-Laos Vietnam (CLV)
    - Asian Parliamentary Assembly (APA)
    - Asian Pacific Parliamentary Forum (APPF)
- Friendly Groups of the Senate of the Kingdom of Cambodia with parliaments of other countries (bilateral):
    - Parliaments of the Republic of France
    - The Parliament of Federation Wallone-Bruxels
    - The National Assembly of the People Democratic Republic of Laos
    - The National Assembly of the Socialist Republic of Vietnam
    - National People's Congress of the People Republic of China
    - Japanese Diet
    - The Parliament of Australia and New Zealand
    - The National Assembly of Thailand
    - Grand National Assembly of Turkey
    - State Duma of Russia
    - State Great Khural (Mongolian parliament)
    - The National Assembly of the Republic of Korea
    - Parliament of India
    - Assembly of the Union of Myanmar

The Committee on Code of Conduct and these friendly groups of the Senate exercise their business in line with their roles, duties and competences as well as their monthly budget regimes which shall be defined by the Permanent Committee.

## 2. Administrative Structure

In early of each legislature after the election of leaders of the Senate, the President, with consents of the two Vice-Presidents, proposes to His Majesty the King to appoint a senior dignitary as Secretary General and a number of deputy Secretary Generals based on the necessity to functioning the Secretariat General of the Senate.

The Secretariat General of Senate is in charge of development of minutes of the Senate, Permanent Committee and Commissions of the Senate, administrative works, and services of the Senate as well as external relations of the Senate under the leadership and supervision of the President of the Senate.

